អង្គការសហប្រជាជាតិ

A/HRC/31/66

# មហាសន្និបាត

ចែកចាយ: ទូទៅ
ថ្ងៃទី៤ កុម្ភៈ ២០១៦

ច្បាប់ដើម: អង់គ្លេស
បកប្រែ ក្រៅផ្លូវការជាភាសាខ្មែរ
មិនមែនដោយអង្គការសហប្រជាជាតិ
UNOFFICIAL KHMER TRANSLATION;
NOT TRANSLATED BY THE UNITED
NATIONS

ក្រុមប្រឹក្សាសិទ្ធិមនុស្ស
សម័យប្រជុំលើកទី៣១
របៀបវារៈ ៣
លើកស្ទួយ និងការពារសិទ្ធិមនុស្សទាំងអស់រួមមាន សិទ្ធិ
ពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
រួមទាំងសិទ្ធិអភិវឌ្ឍន៍

## របាយការណ៍រួម របស់អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិទទួលបានសេរីភាពនៃការប្រជុំដោយសន្តិវិធីនិងសិទ្ធិចូលរួមបង្កើតសមាគមនិងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ភ្លាមៗឬតាមអំពើចិត្តក្រៅប្រព័ន្ធតុលាការ អំពីការគ្រប់គ្រងត្រឹមត្រូវនៃការប្រជុំ

កំណត់សម្គាល់ដោយលេខាធិការដ្ឋាន

លេខាធិការដ្ឋានមានកិត្តិយសផ្ញើរជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នូវរបាយការណ៍រួមគ្នារបស់អ្នករាយការណ៍ពិសេស**ម៉ៃណាគីអាយ**(MainaKiai)ស្តីពីសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធី និងសិទ្ធិចូលរួមបង្កើតសមាគម និង អ្នករាយការណ៍ពិសេស**គ្រីស្តូពហ៊ិនស៍**(Christof Heyns)ស្តីពីការសម្លាប់ភ្លាមៗឬតាមអំពើចិត្ត ក្រៅប្រព័ន្ធតុលាការ។ ក្នុងរបាយការណ៍នេះ ដែលបានផ្ញើរជូនក្រុមប្រឹក្សា យោងតាមសេចក្តី សម្រេចចិត្តរបស់ខ្លួនលេខ២៥/៣៨ អ្នករាយការណ៍ពិសេសដាក់ជូនកម្រងអនុសាសន៍អនុវត្ត សម្រាប់ការគ្រប់គ្រងត្រឹមត្រូវនៃការប្រជុំ ក្នុងផ្នែកនីមួយនៃកម្រងអនុសាសន៍ អ្នករាយការណ៍ពិសេស ផ្តល់សេចក្តីសង្ខេបនៃបទដ្ឋានអនុវត្តច្បាប់ អន្តរជាតិ និងមានជាលំដាប់អនុសាសន៍អនុវត្តជាក់ស្តែង ស្តីពីវិធីសាស្ត្រអនុវត្ត គោលការណ៍ទាំងនោះ ក្នុងគោលបំណងធានាការការពារកាន់ប្រសើរ ចំពោះសិទ្ធិផ្សេងៗ របស់បុគ្គលដែលចូលរួមប្រជុំ។

GE.16-01527(E)
*1601527*

Please recycle

## មាតិកា

*ទំព័រ*


I. សេចក្តីផ្តើម ........ 3

II. ការគ្រប់គ្រងត្រឹមត្រូវនៃការប្រជុំ ........ 4

ក. រដ្ឋត្រូវគោរពនិងធានារាល់សិទ្ធិទាំងអស់របស់បុគ្គលដែលចូលរួមប្រជុំ ........ 6

ខ. បុគ្គលគ្រប់រូបមានសិទ្ធិដែលមិនអាចដកហូតបានក្នុងការចូលរួមប្រជុំដោយសន្តិវិធី ........ 8

គ. ការដាក់កំហិតលើការប្រជុំដោយសន្តិវិធីត្រូវអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ........ 12

ឃ. រដ្ឋត្រូវសម្របសម្រួលការប្រើប្រាស់សិទ្ធិនៃការប្រជុំដោយសន្តិវិធី ........ 15

ង. មិនត្រូវប្រើប្រាស់កម្លាំងដាច់ខាត ប្រសិនមិនអាចបញ្ចៀសបាន ហើយប្រសិនត្រូវប្រើនោះត្រូវអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ........ 19

ច. បុគ្គលគ្រប់រូបត្រូវមានសិទ្ធិសង្កេតការណ៍ ត្រួតពិនិត្យ និងកត់ត្រាការប្រជុំ ........ 25

ឆ. ការប្រមូលព័ត៌មានផ្ទាល់ខ្លួនដែលទាក់ទងនឹងការប្រជុំ មិនអនុញ្ញាតឲ្យជ្រៀតជ្រែកក្នុងជីវិតឯកជន ឬសិទ្ធិអ្នកដទៃ ........ 27

ជ. បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានដែលទាក់ទងនឹងការប្រជុំ ........ 29

ឈ. សហគ្រាសធុរកិច្ច មានការទទួលខុសត្រូវ គោរពសិទ្ធិមនុស្សក្នុងបរិបទការប្រជុំ ........ 31

ញ. រដ្ឋនិងស្ថាប័នត្រូវចាប់បង្ខំឲ្យទទួលខុសត្រូវចំពោះសកម្មភាពខ្លួនទាក់ទងនឹងការប្រជុំ ........ 33

III. សេចក្តីសន្និដ្ឋាន ........ 36

## I. សេចក្តីផ្តើម:

១. ការប្រជុំដែលមានទម្រង់ផ្សេងៗគ្នា នៅក្នុងពិភពលោកសព្វថ្ងៃនេះ មានតួនាទីយ៉ាងសំខាន់មួយ ដោយផ្តល់ឱកាសនិងភាពប្រឈមថ្មីៗ ការយល់ដឹងច្បាស់លាស់អំពីការអនុវត្តបទដ្ឋាននិងច្បាប់អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស និងបទពិសោធន៍ក្នុងការគ្រប់គ្រងនៃការប្រជុំ ទៅតាមកាលវេលា គឺអាចជួយការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលគ្រប់រូបដែលចូលរួម – អ្នកចូលរួម ប្រជុំ អ្នកឈរមើល អ្នកសង្កេតការណ៍ និងអាជ្ញាធរ។

២.ក្រុមប្រឹក្សាសិទ្ធិមនុស្សបានប្តេជ្ញាប្រឹងប្រែងយកចិត្តទុកដាក់បន្ថែមដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្សនៅក្នុងបរិបទប្រជុំ[1]។ នៅក្នុងខែមីនា ឆ្នាំ២០១៤ ក្រុមប្រឹក្សាបានអនុម័តសេចក្តីសម្រេចចិត្តលេខ២៥/៣៨ ដែលក្នុងនោះ ក្រុមប្រឹក្សា បានស្នើសុំអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពក្នុងការប្រជុំដោយសន្តិវិធីនិងសិទ្ធិចូលរួមបង្កើតសមាគម និង អ្នករាយការណ៍ពិសេសផ្នែក នៃការសម្លាប់ភ្លាមៗ ឬ តាមអំពើចិត្តក្រៅប្រព័ន្ធតុលាការ ដើម្បីចងក្រង អនុសាសន៍សម្រាប់ការគ្រប់គ្រងឲ្យបានត្រឹមត្រូវអំពីការប្រជុំ[2]

៣. ក្នុងការអភិវឌ្ឍអនុសាសន៍ ទៅតាមការស្នើរសុំដោយក្រុមប្រឹក្សា អ្នករាយការណ៍ពិសេសបានពិគ្រោះយោបល់យ៉ាងច្រើនលើសលប់ ជាមួយភាគីពាក់ព័ន្ធ អ្នករាយការណ៍ពិសេសបានធ្វើការពិគ្រោះបូនលើក ជាមួយតំណាងរដ្ឋ[3] និងបួនលើកក្នុងថ្នាក់តំបន់ជាមួយសង្គមស៊ីវិល ស្ថាប័ន វេទិកាសិទ្ធិមនុស្សថ្នាក់ជាតិ យន្តការសិទ្ធិមនុស្សថ្នាក់តំបន់និងការឈ្លបយកការណ៍និងជាមួយជំនាញការដទៃទៀត[4]

---

[1] សូមអាន See A/HRC/19/40, A/HRC/22/28, និង A/HRC/25/32 និង Corr.1.

[2] ជំនួយរបស់Eleanor Jenkin and Kathleen Hardy ក្នុងការសរសេររបាយការណ៍នេះ សម្រេចបានដោយអំណរគុណ។

[3] ការប្រជុំលើកដំបូង ត្រូវបានប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ នៅខែមិថុនា ២០១៥។ លទ្ធផលបានពីការស្នើឡើងពីសំណាក់រដ្ឋអំឡុងពេលប្រជុំ ការពិគ្រោះយោបល់ថ្នាក់តំបន់ត្រូវបានធ្វើឡើង សម្រាប់រដ្ឋពីទ្វីបអាហ្រ្វិក និងមជ្ឈឹមបូពា(Pretoria) និងតំបន់អាស៊ីប៉ាស៊ីភិច (ទីក្រុងអ៊ីស្តានប៊ុល ប្រទេសទួកគី)។ កិច្ចពិគ្រោះយល់បល់លើកចុងក្រោយ សម្រាប់រដ្ឋទាំងអស់ត្រូវបានកោះប្រជុំនៅទីក្រុងហ្សឺណែវ នៅខែតុលា ២០១៥ ដែលមានរដ្ឋចំនួន៥៤ បានចូលរួម។

[4] ការពិគ្រោះយោបល់ទាំងនេះ បានកើតឡើង នៅទីក្រុងសាំងទីយ៉ាកូ (ទ្វីបអាមេរិក និងការាបៀន), និងព្រីទូរីយ៉ា (អាហ្រ្វិក និងមជ្ឈឹមបូពា) ទីក្រុងអ៊ីស្តានប៊ុល ប្រទេសទួកគី (អាស៊ី ប៉ាស៊ីភិច) និងទីក្រហ្សឺណែវ (អឺរ៉ុប និងអាស៊ីកណ្តាល)។ ជំនាញការជាង៩០នាក់បានចូលរួមក្នុងកិច្ចពិគ្រោះយោបល់នេះ។

ប្រឹក្សាដែលមានសមាជិកប្រាំបួននាក់ បានកោះប្រជុំ ហើយផ្តល់មតិត្រឡប់មកកាន់អ្នករាយការណ៍ពិសេស ទៅតាមតំណាក់កាលផ្សេងៗ នៃដំណើរការ[5]

៤. ការចងក្រងនេះ មានបំណងផ្តល់ការណែនាំ នូវវិធីអនុវត្តបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលអាចប្រតិបត្តិនៅក្នុងច្បាប់ក្នុងស្រុក និងការអនុវត្តជាក់ស្តែង ដើម្បីធានាការការពារសិទ្ធិកាន់តែប្រសើរឡើង។ អនុសាសន៍ ត្រូវបានរៀបចំ នៅជុំវិញគោលការណ៍សំខាន់ៗម ប្រមាណ ១០គោលការណ៍។ នៅ ក្នុងផ្នែកនីមួយៗនាំមុខដោយការសង្ខេបនៃបទដ្ឋានអនុវត្ត។ ការអភិវឌ្ឍអនុសាសន៍ យោងតាមបទពិសោធន៍ជាសាកល និងមេរៀនបទពិសោធន៍។

## II. ការគ្រប់គ្រងត្រឹមត្រូវនៃការប្រជុំ

៥. លទ្ធភាពជួបប្រជុំគ្នា និងធ្វើសកម្មភាពរួមគ្នា គឺមានសារៈសំខាន់ជាអាយុជីវិតចំពោះការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ សេដ្ឋកិច្ច សង្គមកិច្ច និងអភិវឌ្ឍន៍ផ្ទាល់ខ្លួន វាសំខាន់ចំពោះការសម្តែងមតិនិងការពង្រឹងការចូលរួមរបស់ពលរដ្ឋ។ការប្រជុំអាចផ្តល់ជាបច្ច័យវិជ្ជមានចំពោះការអភិវឌ្ឍនៃប្រព័ន្ធលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត មានតួនាទីជាមូលដ្ឋាន នៅក្នុងការចូលរួមរបស់សាធារណជន ចាប់បង្ខំឲ្យរដ្ឋាភិបាលទទួលខុសត្រូវ និងការសម្តែងសុឆន្ទៈរបស់ប្រជាជនដែលជាផ្នែកដំណើរការលទ្ធិប្រជាធិបតេយ្យ

៦. ការប្រជុំគឺជាឧបករណ៍មួយផងដែរ តាមរយៈនេះគេអាចសម្តែងអំពីសិទ្ធិសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ ពលរដ្ឋ សិទ្ធិវប្បធម៌ និងសិទ្ធដទៃទៀត។មានន័យថាវា អាចមានតួនាទីសំខាន់ដើម្បីការពារនិងលើកស្ទួយសិទ្ធិមនុស្សក្នុងវិសាលភាពធំទូលាយមួយ។ វាអាចជាឧបករណ៍បំពងសម្លេងប្រជាជនដែលគេមិនសូវអើពើឬអ្នកដែលផ្តល់ ជម្រើសក្នុងការបង្កើត ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនិងនយោបាយ។ ការប្រជុំផ្តល់របៀបនៃប្រាស្រ័យទាក់ទងគ្នា មិនត្រឹមតែជាមួយរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែជាមួយអ្នកដែលមានអំណាចក្នុងសង្គម រួមមានសារជីវកម្ម ស្ថាប័នសាសនា អប់រំ និង វប្បធម៌ និងជាមួយមតិសាធារណៈជនទូទៅ។

៧. ការប្រើសិទ្ធិសេរីភាពដោយសេរីនិងពេញលេញក្នុងការប្រជុំដោយសន្តិវិធី គឺអាចធ្វើទៅបានតែក្នុងកាលៈទេសៈ លទ្ធភាពផ្តល់សិទ្ធិនិងបរិស្ថានសន្តិសុខ កើតមាន

[5] សមាជិកនៃវេទិកាពិគ្រោះយោបល់ មាន : Otto Adang; Stuart Casey-Maslen; Gastón Chillier; AnaraIbraeva; Asma Jahangir; Neil Jarman; Nicholas Opiyo; AmbigaSreenevasan; និងJürgWichtermann.

សម្រាប់សាធារណជនទូទៅ រួមទាំងសង្គមស៊ីវិលនិងអ្នកការពារសិទ្ធិមនុស្សវាកើតឡើងនិងកាលៈទេសៈ សម្រាប់ការចូលរួមរបស់សាធារណជន គ្មានការដាក់កំរិតមិនសមហេតុសមផល ឬហួសហេតុពេក។ ការរាំងរាំង ចំពោះការបង្កើតនិងប្រតិបត្តិសមាគមការការពារដែលទន់ខ្សោយចំពោះពីការសងសឹកវិញចំពោះជនទាំងឡាយដែលអនុវត្តនិងការពារសិទ្ធិមនុស្ស ការដាក់ទណ្ឌកម្មច្រើនហួសកំរិត និងមិនសមាមាត្រទៅនឹងការរំលោភច្បាប់ និងការដាក់កំហិតមិនសមហេតុផលទៅលើការប្រើប្រាស់ទីធ្លា

សាធារណៈ គឺទាំងអស់នោះ ជះឥទ្ធិពលអវិជ្ជមានមកលើសិទ្ធិ សេរីភាព នៃការប្រជុំដោយសន្តិវិធី។

៨. ការគ្រប់គ្រងដែលត្រឹមត្រូវទៅលើការប្រជុំ តម្រូវឲ្យភាគីចូលរួមទាំងអស់ទទួលបានការការពារនិងទទួលបានវិសាលភាពទូលំទូលាយនៃសិទ្ធិបុគ្គលទាំងឡាយដែលចូលរួមក្នុងការប្រជុំ គឺទទួលបានសិទ្ធិការពារមួយចំនួន ដែលសិទ្ធិទាំងនោះរួមមាន៖ សេរីភាពប្រជុំគ្នាដោយសន្តិវិធី ការសម្តែងមតិ សមាគម និងជំនឿ ការចូលរួមក្នុងកិច្ចការសារធារណៈ សិទ្ធិបូរណភាពរាងកាយ រួមមានសិទ្ធិទទួលបានសន្តិសុខសិទ្ធិសេរីភាពរួចផុតពីទណ្ឌកម្ម ឬការប្រព្រឹត្ត មកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប និងសិទ្ធិរស់រានមានជីវិត សេចក្តីថ្លៃថ្នូរជីវិតឯកជន និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ចំពោះការរំលោភសិទ្ធិមនុស្សទាំងអស់។

៩. ទោះបើអ្នកចូលរួមនៅក្នុងការប្រជុំមួយ មិនប្រព្រឹត្តដោយសន្តិវិធីក្តី អាស្រ័យហេតុនេះ ពួកគេបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការប្រជុំដោយសន្តិវិធី តែពួកគេរក្សាទុកសិទ្ធិទាំងអស់ដទៃទៀតចំពោះការកំណត់ធម្មតា ដូច្នេះគ្មានការប្រជុំណាមួយ ដែលគ្មានការការពារទេ។

១០. តាមការយល់ឃើញជាទូទៅ "ការប្រជុំ"មួយគឺជាការប្រមូលផ្តុំគ្នា បណ្តោះអាសន្ននៅក្នុងទីធ្លាឯកជនឬសាធារណៈ និងមានគោលបំណងច្បាស់។ ការប្រជុំនេះអាចមានទ្រង់ទ្រាយជាបាតុកម្ម ការប្រជុំពិភាក្សា កូដ្ឋកម្ម ក្បួនហែរ ការប្រមូលផ្តុំគ្នាឬការអង្គុយនឹងកន្លែង ដោយមានបំណង សម្តែងកើតទុក្ខមិនសុខចិត្តនិងប្រាថ្នា ឬអបអរសាទរ (សូមមើលA/HRC/20/27 កឋាខណ្ឌ២៤)។ ទោះបីកម្មវិធីកីឡាការប្រគំតន្ត្រីនិងការប្រមូលផ្តុំដទៃទៀត ក៏អាចរាប់បញ្ចូលបានដែរ។ ការប្រជុំមួយដែលត្រូវបានកំណត់ថាជាការប្រមូលផ្តុំបណ្តោះអាសន្ន ប៉ុន្តែវាអាចជាបាតុកម្មរយៈពេលវែងដូចជាការអង្គុយតវ៉ានៅនឹងកន្លែង ដែលបង្ហាញអំពីរបៀប "កាន់កាប់"ទីកន្លែងមួយ។ ជាទូទៅ ទោះបីគេយល់ថា ការប្រជុំគឺជាការប្រមូលផ្តុំនៃផ្នែករាងកាយមនុស្ស

តែត្រូវបានទទួលស្គាល់ថាការការពារសិទ្ធិមនុស្ស រួមមានសេរីភាពនៃការប្រជុំ អាចប្រៀបធៀបទៅនឹងអន្តរកម្មរវាងគ្នា នៅតាមប្រព័ន្ធអ៊ិនធឺណិត។

១១. អនុសាសន៍ទាំងនេះ ផ្តោតលើការប្រជុំ ដែលបញ្ជាក់អំពីមុខងារជាទូទៅ អំពីការទួញសោក អំពីក្តីប្រាថ្នា ឬអត្តសញ្ញាណ និងផ្តោតលើការប្រជុំ ដែលផ្ទុយពីតួនាទីទូទៅ ឬដែលប្រឈមនឹងផលប្រយោជន៍នានា ដែលមានយូរលង់មកហើយ ដូចជាផលប្រយោជន៍នយោបាយ សង្គមកិច្ច វប្បធម៌ ឬសេដ្ឋកិច្ច។ ក្នុងការអនុម័តវិធីសាស្ត្រនេះ អ្នករាយការណ៍ពិសេសបាននិងកំពុងអនុវត្តតាមភាសាដែលបានប្រើនៅក្នុងសេចក្តីសម្រេចចិត្ត២៥/៣៨ដែលក្រុមប្រឹក្សាបានយោងជាពិសេសទៅលើការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស នៅក្នុងបរិបទនៃការតវ៉ាដោយសន្តិវិធី។ ទោះជាយ៉ាងណាក្តី គេគួរកត់សម្គាល់ថា គ្មានសិទ្ធិណាមួយដែលអ្នកចូលរួមប្រជុំទទួលបាននោះ ពឹងអាស្រ័យ ទោះបីតាមរយៈណាក្តី លើការសម្តែងចេញអំពីមាតិកានយោបាយ ឬមាតិកាផ្សេងៗ នៅក្នុងការប្រជុំនោះ។

១២. នៅក្នុងសេចក្តីសម្រេចចិត្ត ក្រុមប្រឹក្សា ស្នើឲ្យអ្នករាយការណ៍ពិសេសផ្តោតទៅលើការប្រជុំ ហើយកុំឲ្យបង្រួមតែលើការប្រជុំដោយសន្តិវិធី។ អាស្រ័យហេតុនេះ ទាំងការប្រជុំដោយសន្តិវិធីនិងអសន្តិវិធី គឺមានរាយការណ៍ នៅក្នុង របាយការណ៍បច្ចុប្បន្ន ។

១៣. រដ្ឋ មានកាតព្វកិច្ច មិនត្រឹមតែបញ្ចៀសការរំលោភសិទ្ធិបុគ្គលដែលចូលរួម ក្នុងការប្រជុំប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានានូវសិទ្ធិរបស់បុគ្គលដែលចូលរួម ឬបុគ្គលដែលរងផលប៉ះពាល់ដោយរដ្ឋផងដែរ ហើយត្រូវសម្របសម្រួល បរិយាកាសឲ្យកាន់តែមានលទ្ធភាព។ ពោលគឺ ការគ្រប់គ្រងនៃការប្រជុំបញ្ចូលគ្នានូវការសម្របសម្រួលនិងការផ្តល់លទ្ធភាព ហើយការគ្រប់គ្រងនេះត្រូវបានបកស្រាយយ៉ាងទូលំទូលាយនៅក្នុងអនុសាសន៍ខាងក្រោមនេះ។

## ក. រដ្ឋត្រូវគោរពនិងធានារាល់សិទ្ធិទាំងអស់របស់បុគ្គលដែល ចូលរួមប្រជុំ

១៤. ច្បាប់អន្តរជាតិ តម្រូវឲ្យរដ្ឋទាំងអស់ត្រូវគោរពនិងធានាសិទ្ធិរបស់បុគ្គល គ្រប់រូប។ កាតព្វកិច្ចគោរពសិទ្ធិមានន័យថារដ្ឋត្រូវបញ្ចៀសការដាក់កំហិត ទៅលើការប្រើប្រាស់សិទ្ធិ ដែលច្បាប់អន្តរជាតិបញ្ជាក់ច្បាស់ថាមិនអនុញ្ញាត។ កាតព្វកិច្ចធានា គឺជាភារកិច្ចវិជ្ជមានមួយ ដែលតម្រូវឲ្យរដ្ឋ បំពេញផងនិង ការពារសិទ្ធិផង[6] ។ ការការពារសិទ្ធិ

[6] តុលាការសិទ្ធិមនុស្សរបស់សហគមន៍អឺរ៉ុប , *PlattformÄrtzefür das Leben v. Austria,* ការអនុវត្តលេខ១០១២៦/៨២, ថ្ងៃទី២១ មិថុនា ១៩៨៨

តម្រូវឲ្យចាត់វិធានការវិជ្ជមាន ក្នុងការបង្ការសកម្មភាពរបស់តួអង្គដែលមិនមែនរដ្ឋ ដែលសកម្មភាព នោះអាចរំខានដល់ការប្រើប្រាស់របស់ពួកគេ។ ការបំពេញសិទ្ធិ តម្រូវរដ្ឋឲ្យបង្កើត សម្របសម្រួល ឬផ្តល់ល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់ការទទួលបានសិទ្ធិ។

១៥. រដ្ឋត្រូវគោរពនិងធានាសិទ្ធិ ដោយគ្មានការរើសអើង ផ្អែកលើការហាមប្រាម រួមមានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬផ្សេងៗ ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងៗទៀត។ សេរីភាពក្នុងការរៀបចំនិងចូលរួមក្នុងការប្រជុំសាធារណៈ ត្រូវបានធានាចំពោះបុគ្គល គ្រប់រូប ក្រុម សមាគមដែលមិនបានចុះបញ្ជី ស្ថាប័នស្របច្បាប់ និងស្ថាប័នសារជីវកម្ម[7]

១៦. គួរខិតខំប្រឹងប្រែងពិសេស ដើម្បីធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាព និងស្មើរភាព នៃសិទ្ធិរបស់ក្រុមឬបុគ្គល ដែលធ្លាប់ទទួលរងនឹងការរើសអើងយូរអង្វែង រួមមានស្ត្រី កុមារ និងពលរដ្ឋវ័យក្មេង ជនពិការ ជនដែលមិនមែនជាពលរដ្ឋរបស់ខ្លួន (អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន) សមាជិកនៃជនជាតិភាគតិច ឬ សាសនា ជនដែលផ្លាស់ទីលំនៅ បុគ្គលភៀកសម្បុរស ជនជាតិដើមភាគតិច និងបុគ្គលដែលរងការរើសអើង ដោយផ្អែកលើភេទនិងយ៉ែនឌឺរបស់ខ្លួន (A/HRC/26/29)។ ភារកិច្ចនេះ តម្រូវអាជ្ញាធរឲ្យចាត់វិធានការបន្ថែម ដើម្បីការពារនិងសម្រួលការប្រើសិទ្ធិ សេរីភាពនៃការប្រជុំ ដោយក្រុមទាំងនោះ។

១៧. **អនុសាសន៍អនុវត្តៈ**

(ក) រដ្ឋគួរឲ្យសច្ចប័នលើសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ និងគួរបង្កើតការ សន្មត់វិជ្ជមាននៅក្នុងច្បាប់ ដែលជាប្រយោជន៍ដល់ការប្រជុំដោយសន្តិវិធី។ ពួកគេគួរ ផ្តល់កិច្ចការពារផ្លូវច្បាប់ ចំពោះសិទ្ធិផ្សេងៗគ្នា ដែលការពារបុគ្គល ទាំងឡាយ ចូលរួម ប្រជុំ ផ្តល់លទ្ធភាព និង បន្តធ្វើបច្ចុប្បន្នភាពនូវច្បាប់ គោលនយោបាយ និងដំណើរការ ចាំបាច់សម្រាប់អនុវត្តសិទ្ធិទាំងនេះ។ មិនត្រូវចាត់ទុកការប្រជុំណាមួយ ជាការប្រជុំដែល គ្មានការពារទេ។

(ខ) រដ្ឋ គួរធានាថាពង្រាងច្បាប់ទាំងអស់ដែលទាក់ទងនឹងការគ្រប់គ្រង ការប្រជុំ មិនត្រូវមានន័យបង្កប់ទេ ពង្រាងច្បាប់ត្រូវដូចៗគ្នា និងតាមបទដ្ឋានអន្តរជាតិ។ ប្រសិនបើមានន័យបង្កប់ ត្រូវបកស្រាយបទបញ្ញត្តិទាំងឡាយដែលផ្តល់ ប្រយោជន៍ដល់ ជនដែលប្រាថ្នាចង់ប្រើសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការចូលរួមប្រជុំដោយ សន្តិវិធី។

[7] សូមមើល ការិយាល័យ សម្រាប់ស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODIHR) នៃអង្គការ សម្រាប់សន្តិសុខនិងប្រតិបត្តិការនៅអឺរ៉ុប (OSCE), *គោលការណែនាំ ស្តីពីសេរីភាពនៃការប្រជុំគ្នាដោយសន្តិវិធី* (២០១០), ២.៥

(គ) រដ្ឋ គួរអភិវឌ្ឍ អនុម័ត និងធ្វើបច្ចុប្បន្នភាព អំពីផែនការសកម្មភាពថ្នាក់ជាតិ ដើម្បីអនុវត្តអនុសាសន៍បច្ចុប្បន្ន និងអភិវឌ្ឍបទដ្ឋានអន្តរជាតិ ដែលទាក់ទងទៅនិងការគ្រប់គ្រងការប្រជុំ និងគួរស្វែងរកជំនួយបច្ចេកទេស ពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ឬភ្នាក់ងារឯកទេស ដែលសមស្រប ដទៃទៀត

(ឃ) រដ្ឋគួរផ្តល់ការគាំទ្រជាចាំបាច់ចំពោះ និងការត្រួតពិនិត្យគ្រប់គ្រាន់ទៅលើអាជ្ញាធររដ្ឋាភិបាលនៅគ្រប់ជាន់ថ្នាក់ ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងការប្រជុំ។ ចំណុចនេះរួមមានការបណ្តុះបណ្តាលគ្រប់គ្រាន់និងធនធានមនុស្ស និងហិរញ្ញវត្ថុដែលចាំបាច់។

(ង) អ្នកដឹកនាំនយោបាយនិងវិស័យផ្សេងទៀត គួរទទួលស្គាល់ជា សាធារណៈថាមតិផ្ទុយគ្នាពិតជាមាន ហើយគួរលើកស្ទួយវប្បធម៌អត់ឱន។

## ខ. មនុស្សគ្រប់រូបមានសិទ្ធិដែលមិនអាចដកហូតបាន ក្នុងការចូលរួមប្រជុំដោយសន្តិវិធី

១៨. ពីព្រោះច្បាប់អន្តរជាតិទទួលស្គាល់សិទ្ធិដែលមិនអាចដកហូតបាន ដើម្បីចូលរួមប្រជុំដោយសន្តិវិធី ច្បាប់ចែងថាមានការសន្មត់ជាមុន ដែលជាប្រយោជន៍ដល់ការរៀបចំប្រជុំដោយសន្តិវិធី។ ការប្រជុំទាំងអស់គួរត្រូវបានសន្មត់ស្របច្បាប់ យោងតាម ការដាក់កម្រិតដែលអនុញ្ញាត ដែលកំណត់ក្នុងមាត្រា២១នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[8] ។ កិច្ចការពារសិទ្ធិសេរីភាពក្នុងការប្រជុំដោយសន្តិវិធី គឺភ្ជាប់នឹងការប្រជុំណាដែលប្រព្រឹត្តដោយសន្តិវិធីតែប៉ុណ្ណោះ។ ក្នុងការកំណត់ថាការប្រជុំមួយដែលមានការការពារដោយច្បាប់នេះឬយ៉ាងណានោះ គឺគួរសន្មត់[9]ភាពក្សេមក្សាន្តនៃការប្រជុំ និងគួរមានការបកស្រាយពាក្យ "សន្តិវិធី" [10] ឲ្យបានទូលាយ។ ត្រូវផ្តល់ការគោរពទន្ទឹងវិយាបថនៃកិច្ចប្រជុំដែលបាន ធ្វើ និងចំពោះបំណងរបស់អ្នកចូលរួម។

១៩. សិទ្ធិសេរីភាពក្នុងការប្រជុំដោយសន្តិវិធី រួមមានសិទ្ធិធ្វើផែនការ ចាត់ចែង លើកស្ទួយ និង ប្រកាសផ្សាយ អំពីការប្រជុំតាមរៀបមួយដែលស្របច្បាប់។ ការដាក់កំហិត ណាមួយទៅលើសកម្មភាពបែបនេះ ត្រូវបានចាត់ទុកថាជាការដាក់កំហិតជាមុនលើការប្រើប្រាស់សិទ្ធិ។ ការដាក់កំហិតទៅលើសេរីភាពបង្កើតសមាគម និងការ

---

8 សូមមើល A/HRC/23/39, កឋាខណ្ឌ៥០, និង OSCE, គោលការណ៍, កឋាខណ្ឌ៣០

9 សូមមើល A/HRC/20/27, កឋាខណ្ឌ២៦, និង A/HRC/23/39, កឋាខណ្ឌ៥០

10 Manfred Nowak, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយៈបទអត្ថាធិប្បាយ (Kehl am Rhein, Engel, 2005),ទព. ៤៨៧.

សម្តែងមតិ អាចបម្រើគោលបំណង ដើម្បីសម្រេចបាន នូវក្នុងការដាក់កំហិត ដោយប្រសិទ្ធភាពទៅលើ សេរីភាពចូលរួមក្នុងការប្រជុំដោយសន្តិវិធី។

២០. សិទ្ធិសេរីភាពចូលរួមប្រជុំដោយសន្តិវិធី គឺរក្សាទុកដោយបុគ្គលគ្រប់ៗគ្នា ដែលចូលរួមប្រជុំ។ សកម្មភាពអំពើហិង្សាឬការរំលោភ បំពានម្តងម្កាល ដែលបង្កដោយជនមួយចំនួន មិនគួរសំដៅមកលើអ្នកដទៃ ដែលមានបំណង និងឥរិយាបថរក្សាភាពក្បែមក្សាន្តទេ[11]។

២១. សេរីភាពចូលរួមប្រជុំដោយសន្តិវិធី គឺជាសិទ្ធិ និងមិនមែនជាអភ័យឯកសិទ្ធិ ហេតុនេះហើយ ការប្រើប្រាស់សិទ្ធនេះ មិនមែនជាកម្មវត្ថុស្នើសុំការអនុញ្ញាតជាមុនពីអាជ្ញាធរទេ។ អាជ្ញាធររបស់រដ្ឋ អាចដាក់ដំណើរការនូវប្រព័ន្ធមួយអំពីការជូនដំណឹងជាមុន ក្នុងគោលបំណងផ្តល់ឱកាសដល់អាជ្ញាធររដ្ឋាភិបាល ជួយសម្រួលដល់ការប្រើប្រាស់សិទ្ធិ ដើម្បីចាត់វិធានការការពារសុវត្ថិភាពសាធារណៈ និង/ឬសណ្តាប់ធ្នាប់សាធារណៈ និងការពារសិទ្ធិសេរីភាពរបស់អ្នកដទៃ។ នីតិវិធីជូនដំណឹង មិនត្រូវបំពេញការស្នើសុំការអនុញ្ញាតដែលមានក្នុងច្បាប់ ឬ ជាមូលដ្ឋានសម្រាប់កំនត់មាតិកាទេ។ អាជ្ញាធររដ្ឋាភិបាលមិនគួររំពឹង ទាមទារការជូនដំណឹងអំពីការប្រជុំទេ ដែលមិនចាំបាច់ឲ្យមានការរៀបចំជាមុន ដោយសារចំនួនអ្នកចូលរួមមានតិចតួច ឬផលប៉ះពាល់លើសាធារណៈមានទំហំតូច។

២២. គោលការណ៍ជូនដំណឹង មិនគួរពាក់ព័ន្ធនឹងបែបបទការិយាធិបតេយ្យច្រើនពេក ហើយគួរផ្អែកលើការវាយតម្លៃតាមសមាមាត្រ[12] ។ រយៈពេលជូនដំណឹងមិនត្រូវយូរពេក ប៉ុន្តែត្រូវទុកពេលគ្រប់គ្រាន់ដល់អាជ្ញាធរពាក់ព័ន្ធ ដើម្បីរៀបចំការប្រជុំឲ្យបានសមស្រប។ វិធីជូនដំណឹង មិនគួរតម្រូវឲ្យបង់កម្រៃ(សូមអាន A/HRC/23/39 កឋាខណ្ឌ៥៧) និងអាចចេញចូលបានដោយទូលំទូលាយ។

២៣. ការខកខានជូនដំណឹងដល់អាជ្ញាធរ អំពីការប្រជុំ មិនបណ្តាលឲ្យការប្រជុំមួយខុសច្បាប់ឡើយ ហើយជាផលវិបាក មិនត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់បំបែកការប្រជុំឡើយ។ ប្រសិនមានការខកខានជូនដំណឹងត្រឹមត្រូវ អ្នកចាត់ចែងមេដឹកនាំនយោបាយ ឬមេសហគមន៍ មិនគួរទទួលរងទណ្ឌកម្មរដ្ឋបាល ឬបទឧក្រិដ្ឋទេ ដែលបណ្តាលឲ្យមានការពិន័យជាប្រាក់ ឬជាប់ពន្ធនាគារ (សូមអាន A/HRC/20/27កឋាខណ្ឌ២៩)។ ត្រង់នេះអនុវត្តដូចគ្នានឹងករណីដែលការប្រជុំកើតឡើង

---

[11] តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Ziliberberg v. Moldova*, អនុវត្តលេខ៦១៨២១/០០, ៤ឧសភា ២០០៤

[12] សូមមើល A/HRC/20/27, កឋាខណ្ឌ២៨ , និងគណកម្មការចម្រុះអាមេរិកាំងស្តីពីសិទ្ធិមនុស្ស *របាយការណ៍ទីពីរស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅទ្វីបអាមេរិក* (២០១១),កឋាខណ្ឌ១៣៧

ភ្លាមៗឥតគ្រោងទុក ប្រសិនការជូនដំណឹងជាមុន មិនអាចអនុវត្តតាមជាក់ស្តែង ឬប្រសិនគ្មានអ្នកចាត់ចែងដែលមិនស្គាល់។ ការប្រជុំភ្លាមៗដោយឥតគ្រោងទុក គួរតែរួចពីល័ក្ខខ័ណ្ឌទាមទារការជូនដំណឹង[13] និងអាជ្ញាធរអនុវត្តច្បាប់ គួរការពារនិងសម្រួលការប្រជុំដែលឥតគ្រោងទុក ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

២៤. កាតព្វកិច្ចរបស់រដ្ឋក្នុងការសម្រួលនិងការពារការប្រជុំ រាប់បញ្ចូលការប្រជុំ និងការតវ៉ាមួយដែលប្រឆាំងនឹងការប្រជុំ ដែលកើតឡើងក្នុងពេលដូចគ្នា ក្នុងនោះការប្រជុំមួយ ឬច្រើនមានបំណងសម្តែងការមិនសប្បាយចិត្ត ចំពោះ សាររបស់ ការប្រជុំរបស់ក្រុមផ្សេងមួយទៀត។ ការប្រជុំ រួមមានការប្រជុំដែលឥតគ្រោងទុក និងការតវ៉ាប្រឆាំងការប្រជុំ គួរមានការសម្របសម្រួលតាមដែលលទ្ធភាពធ្វើទៅបាន ដើម្បីឲ្យកើតឡើងចំគោលដៅរបស់ខ្លួន[14]។

២៥. កាតព្វកិច្ចសម្របសម្រួលរបស់រដ្ឋ រួមមានវិធានការការពារជនទាំងឡាយដែលប្រើសិទ្ធិរបស់ខ្លួន ឲ្យរួចចាកពីអំពើហិង្សានិងការជ្រៀតជ្រែក[15]។ ទោះជាយ៉ាងណាក្តី វត្តមានហានិភ័យ មិនគ្រប់គ្រាន់សម្រាប់ធ្វើការហាមប្រាម ការប្រជុំទេ[16] ។ ប្រសិនបើមានហានិភ័យនៃការប៉ះទង្គិចគ្នាដោយហិង្សា រវាងអ្នកចូលរួម រវាងក្រុមប្រជុំយ៉ាងហោចណាស់ ត្រូវចាត់វិធានការតឹងរឹង ដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់អ្នកចូលរួម និងអ្នកដទៃទៀត។

២៦. ខណៈដែលអ្នករៀបចំ ខិតខំអនុវត្តតាមច្បាប់ដោយសមហេតុផល និងលើកទឹកចិត្តការប្រជុំ ឲ្យប្រកាន់ឥរិយាបថសន្តិវិធី អ្នករៀបចំនោះមិនគួរត្រូវចាប់បង្ខំឲ្យទទួលខុសត្រូវ ចំពោះឥរិយាបថខុសច្បាប់របស់អ្នកផ្សេងឡើយ[17] ។ ទង្វើដូចនេះគឺរំលោភលើគោលការទទួលខុសត្រូវបុគ្គល ធ្វើឲ្យទំនុកចិត្តចុះខ្សោយ និងសហការរវាងអ្នករៀបចំការប្រជុំនិងអាជ្ញាធរ និងធ្វើឲ្យអ្នករៀបចំការប្រជុំសំខាន់បាក់ទឹកចិត្តក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេ។

---

[13] តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Bukta v. Hungary*,ការអនុវត្តលេខ ២៥៦៩១/០៤, ថ្ងៃទី១៧ កក្កដា ២០០៧

[14] ទោះជាយ៉ាងណាក្តី បើមានបាតុកម្មដែលប្រឆាំង ដែលរៀបចំ ដោយប៉ុនប៉ង ជ្រៀតជ្រែកសិទ្ធិអ្នកដទៃ ដែលបានជួបជុំគ្នាដោយស្របច្បាប់ បាតុកម្មប្រឆាំងនឹងស្ថិតក្នុងឥទ្ធិពលនៃមាត្រា៥នៃកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងការការពារ ចំពោះសិទ្ធិ សេរីភាពនៃការប្រជុំដោយសន្តិវិធី នឹងមិនអនុវត្ត។

[15] សូមមើលតុលាការសិទ្ធិមនុស្សអឺរ៉ុប, *OzgurGundem v. Turkey*, អនុវត្តលេខ២៣១៤៤/៩៣, ១៦ មីនា ២០០០, កឋាខណ្ឌ៤២-៤៣

[16] សូមមើលតុលាការសិទ្ធិមនុស្សអឺរ៉ុប,*Alekseyev v. Russia*, អនុវត្តលេខ ៤៩១៦/០៧, ២៥៩២៤/០៨ និង ១៤៥៩៩/០៩, ២១ តុលា ២០១០, កឋាខណ្ឌ៧៥

[17] សូមមើលរបាយការណ៍ A/HRC/20/27, កឋាខណ្ឌ៣១,និង A/HRC/23/39, កឋាខណ្ឌ៧៨

២៧. គ្មានជនណាម្នាក់ត្រូវបានចាប់បង្ខំឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ រដ្ឋប្បវេណី ឬ រដ្ឋបាលទេ ចំពោះទង្វើដែលគ្រាន់តែរៀបចំ ឬចូលរួមក្នុងការតវ៉ាដោយសន្តិវិធីប៉ុណ្ណោះ

២៨. **អនុសាសន៍អនុវត្តះ**

(a) រដ្ឋ ត្រូវធានាថាប្រព័ន្ធជូនដំណឹងមុន មានអនុភាពទៅលើការសន្មត់ ជាប្រយោជន៍ដល់ការប្រជុំ ។ រដ្ឋត្រូវកម្រិតឆន្ទានុសិទ្ធិ របស់អាជ្ញាធរឲ្យតូចចង្អៀត ដែលដាក់កំហិតមកលើការប្រជុំ និងបញ្ចូលការធ្វើប្រមាណ នៃសមាមាត្រ។

(ខ) រដ្ឋ មិនគួរតម្រូវអ្នករៀបចំឲ្យទទួលបានអនុញ្ញាតជាមុន តាមច្បាប់ ឬតាមការអនុវត្តជាក់ស្តែងក្តី ដើម្បីធ្វើការប្រជុំទេ។ ប្រសិនបើមានប្រព័ន្ធជូនដំណឹង គឺត្រូវជួយសម្រួលដល់ការប្រជុំដោយសន្តិវិធី និងមិនត្រូវអនុវត្ត តម្រូវការតាមច្បាប់ ដើម្បីសុំការអនុញ្ញាតជាមុន

(គ) ប្រព័ន្ធជូនដំណឹង មិនត្រូវមានបែបបទការិយាធិបេតយ្យច្រើនពេក។ វិធានការ ដើម្បីសម្រួលដំណើរការជូនដំណឹង រួមមានះចំនុចទីតាំងស្នាក់នៅចម្រុះ ទាំងនៅក្រៅទីប្រជុំជន កន្លែងស្នាក់នៅផ្ទាល់ខ្លួននិងទីតាំងជំនួយ។ ការប្រើទម្រង់បែបបទដែលងាយរកបាន ដោយសង្ខេប និងមានជាភាសាផ្សេងៗគ្នា។ ប្រសិនសេវាប្រព័ន្ធអ៊ិនធឺណេតខ្លាំង អាជ្ញាធរគួរពិចារណាប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេត តាមទីស្នាក់នៅ។

(ឃ) ពេលវេលាជូនដំណឹងត្រូវមានរយៈពេលខ្លី តាមដែលអាចធ្វើបាន គួរទុកពេលគ្រប់គ្រាន់សម្រាប់អាជ្ញាធរ ដើម្បីរៀបចំការប្រជុំ រយៈពេលច្រើនថ្ងៃយ៉ាងច្រើនបំផុត តាមចិត្តចង់បានគឺក្នុងរង្វង់៤៨ម៉ោង

(ង) ដោយចាត់ទុកថាការជូនដំណឹងត្រូវបានបំពេញសព្វគ្រប់ គឺនៅពេលណាអាជ្ញាធរបានទទួលការជូនដំណឹងមួយដែលផ្តល់ព័ត៌មានគ្រប់គ្រាន់ សម្រាប់ កំណត់ថ្ងៃ វេលានិងទីតាំងនៃការប្រជុំដោយសមហេតុសមផល និងពេលណាទាក់ទង លេខទំនាក់ទំនងលំអិតរបស់អ្នករៀបចំ។ អាជ្ញាធរមិនចាំបាច់ ឆ្លើយតប ដើម្បីបំពេញការជូន ឬឆ្លើយតបឲ្យ ការប្រជុំដំណើរការទេ។

(ច) ប្រសិនការជូនដំណឹង ត្រូវបានដាក់ពាក្យ សម្រាប់ការប្រជុំចំនួនពីរឬ ច្រើន ដែលស្ថិតនៅទីកន្លែងនិងវេលាដូចគ្នា អាជ្ញាធរគួរប្រមាណដោយល្អិតល្អន់ អំពី ហានិភ័យ និងអភិវឌ្ឍយុទ្ធសាស្រ្តសម្រាប់កាត់បន្ថយហានិភ័យទាំងនោះ។ នៅពេល ដែលចាំបាច់ ត្រូវដាក់កំហិតទៅលើការប្រជុំមួយឬច្រើនក្នុងពេលតែមួយ ការដាក់កំហិត ទាំងនោះ

គួរតែសម្រេចតាមរយៈកិច្ចព្រមព្រៀងទាំងសង្ខាង ឬប្រសិន មិនអាចទៅរួច គួរតាមរយៈដំណើរការដែលមិនរើសអើងរវាងការប្រជុំ ដែលបាន ស្នើនោះ។

## គ. ការដាក់កំហិតលើការប្រជុំដោយសន្តិវិធី ត្រូវអនុវត្តតាម បទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស

២៩. សេរីភាពនៃការប្រជុំដោយសន្តិវិធី គឺជាសិទ្ធិមូលដ្ឋាន ហើយគួរតែប្រើប្រាស់វាទៅតាមវិសាលភាពនៃលទ្ធភាពដែលអាចធ្វើទៅបាន ដោយគ្មានការដាក់កំហិត។ នៅក្នុងសង្គមប្រជាធិបតេយ្យ ការដាក់កំហិតត្រូវបានធ្វើឡើង ក្នុងករណីចាំបាច់ប៉ុណ្ណោះ សម្រាប់ប្រយោជន៍សន្តិសុខជាតិ ឬសន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈឬសីលធម៌ ឬការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ ហើយការដាក់កំហិតនោះគឺស្របច្បាប់ ចាំបាច់ និងសមាមាត្រទៅតាមគោលដៅ ដែលខិតខំសម្រេចបាន។ ការដាក់កំហិតខ្លះ គឺជាករណីពិសេស ដែលមិនមែនជាលិខិតបទដ្ឋាន និងមិនត្រូវធ្វើខូចខាតចំពោះខ្លឹមសារនៃសិទ្ធិទេ[18]។

៣០. ដើម្បីបំពេញតម្រូវការនៃនីត្យានុកូលភាព ការដាក់កំហិតណាមួយ ត្រូវមានមូលដ្ឋានស្របច្បាប់និងផ្លូវការនៅក្នុងច្បាប់ (គោលការណ៍នីត្យានុកូលភាព) អាណត្តិនិងអំណាចរបស់អាជ្ញាធរត្រូវដាក់កម្រិតដូចគ្នាដែរ[19] ។ ច្បាប់ខ្លួនឯងហ្នឹង ត្រូវមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ដើម្បីទុកឲ្យបុគ្គលម្នាក់អាចប្រមាណខ្លួន ថាតើខ្លួនបានរំលោភច្បាប់ឬអត់ ហើយអាចប្រមើមើលទៅមុខអំពីផលវិបាកនៃ ការរំលោភដែលអាចកើតមានពីការរំលោភបំពាន[20] ។ ដើម្បីអនុលោមតាមគោលការណ៍ សមាមាត្រ ការដាក់កំហិតត្រូវតែសមស្របក្នុងការបំពេញនូវមុខងារការពាររបស់ខ្លួន។ ដើម្បីបំពេញតម្រូវការចាំបាច់ ត្រូវមានលិខិតូបករណ៍ដែលមិនសូវរំលោភបំពាន នៅក្នុងចំណោមការដាក់កំហិតដែលអាចសម្រេចផលបានតាមបំណង[21] ។ ត្រូវដាក់កំហិត ដែលចង្អៀត មកលើគោលដៅជាក់លាក់ និងការបារម្ភរបស់អាជ្ញាធរ ហើយពិចារណា និងវិភាគទៅលើសិទ្ធិនានា ដែលពាក់ព័ន្ធនឹងការប្រជុំដែលបានស្នើ។ ក្នុងការកំណត់ លិខិតូបករណ៍ដែលមិនសូវបំពាន ដើម្បីសម្រេចផលតាមប្រាថ្នា

[18] សូមមើលគណកម្មការសិទ្ធិមនុស្ស, អត្ថាធិប្បាយទូទៅលេខ ២៧ (១៩៩៩) ស្តីពីសេរីភាពនៃការធ្វើដំណើរ, កឋាខណ្ឌ១៣

[19] សូមមើលOSCE/ODIHR, គោលការណ៍ណែនាំ, កឋាខណ្ឌ៣៥, និងតុលាសិទ្ធិមនុស្សអឺរ៉ុប, *Hyde Park and others v. Moldova*, ការអនុវត្តលេខ. ៣៣៤៨២/០៦, ៣១ មីនា ២០០៩

[20] សូមមើលតុលាសិទ្ធិមនុស្សអឺរ៉ុប,*Hashman and Harrup v. the United Kingdom*, អនុវត្តលេខ ២៥៥៩៤/៩៤, ២៥ វិច្ឆិកា ១៩៩៩, កឋាខណ្ឌ៣១, និង*Gillan and Quinton v. the United Kingdom*, អនុវត្តលេខ ៤១៥៨/០៥, ១២ មករា ២០១០,កឋាខណ្ឌ៧៦

[21] សូមមើលគណកម្មការសិទ្ធិមនុស្ស, ការពន្យល់ទូទៅ លេខ២៧,កឋាខណ្ឌ១៤

អាជ្ញាធរគួរ ពិចារណាទៅ លើវិធានការនានា ដោយយកការហាមប្រាមជាជំរើសចុងក្រោយ។ ឈានដល់ទីបញ្ចប់នៃចំនុចនេះ ការហាមប្រាមដែលប៉ះពាល់ដល់មនុស្សទាំងមូល និងទីធ្លាទាំងមូលរួមទាំងការហាមប្រាមលើការប្រើសិទ្ធិទាំងស្រុង ឬលើការប្រប្រាស់ ទីធ្លាជាក់លាក់ ឬនៅពេលវេលាជាក់លាក់ គឺមិនសមាមាត្រ ពីព្រោះពួកគេច្រាន ចោលការពិចារណាជាមុន អំពីផលវិបាកជាក់លាក់ នៃការប្រជុំនីមួយៗដែលបានស្នើ (សូមមើល A/HRC/23/39 កឋាខណ្ឌ៦៣)

៣១. នៅពេលរដ្ឋមួយយកបញ្ហាសន្តិសុខជាតិ និង ការពារសណ្តាប់ធ្នាប់សាធារណៈជាសំអាង សម្រាប់ដាក់កំហិតលើការប្រជុំ វាស្តែងចេញឲ្យឃើញច្បាស់អំពីសារជាតិគំរាមកំហែង និងហានិភ័យដែលបានដាក់ចេញ[22] ។ វាគ្មានលក្ខណៈគ្រប់គ្រាន់សម្រាប់រដ្ឋ ដើម្បីយោងជាទូទៅ ចំពោះស្ថានភាពសន្តិសុខនោះទេ។ ផលប្រយោជន៍ជាតិ នយោបាយ ឬ ផលប្រជយោជន៍របស់រដ្ឋាភិបាល គឺមិនមានន័យដូចគ្នាទៅនឹងសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈទេ។

៣២. ការប្រើប្រាស់ទីធ្លាសាធារណៈ សម្រាប់ការប្រជុំផ្សេងៗ គឺជារឿងស្របច្បាប់ដោយស្មើភាពគ្នា និងដូចគ្នាទៅនឹងសកម្មភាពពាណិជ្ជកម្ម ឬចលនាចរាចរយានយន្ត និងអ្នកថ្មើរជើង។ ការប្រើប្រាស់ទីសាធារណៈ ទាមទារនូវវិធានការសម្រុមសម្រួលខ្លះដើម្បីការពារផលប្រយោជន៍ខុសៗគ្នា ប៉ុន្តែ មានវិធីស្របច្បាប់ជាច្រើន ដែលបុគ្គលអាចប្រើប្រាស់ទីធ្លាសាធារណៈ។ ការប្រជុំបង្កការរំខានខ្លះដល់ ជីវភាពរស់នៅប្រចាំថ្ងៃ ការធុញទ្រាន់ និងប៉ះពាល់ដល់សកម្មភាពពាណិជ្ជកម្ម ។ ត្រូវអត់អោន ប្រសិនបើខ្លឹមសារនៃសិទ្ធិមិនត្រូវបានដកហូត[23]។

៣៣. អ្នកចូលរួមប្រជុំ មានសេរីភាពជ្រើសរើសនិងសម្តែងអំពីសាររបស់ខ្លួន។ ការដាក់កំហិតលើមាតិកាសារនៃការប្រជុំ ត្រូវតែអនុលោមតាមការកំណត់ដែលបញ្ញត្តិមកលើសិទ្ធិ ដែលបានចែងខាងលើ ឧទាហរណ៍ ប្រសិនសារនោះគាំទ្រការស្អប់ជាតិសាសន៍ ឬសាសនា ដែលបង្កើតជាការញុះញង់ការរើសអើង អរិយភាព និងអំពើហិង្សា។ ប្រើសិនបើការដាក់កំហិតលើមាតិកា បង្ហាញថាត្រឹមត្រូវសមហេតុផល អាជ្ញាធរគួរចាត់វិធានការដាក់កំហិតដែលមានលក្ខណៈមិនសូវរំលោភបំពាន ដើម្បីដោះស្រាយបញ្ហា។

---

22 សូមមើលគណកម្មការសិទ្ធិមនុស្ស, ទំនាក់ទំនងលេខ ១១១៩/២០០២, *លី v.សាធារណរដ្ឋកូរ៉េ*, ពិនិត្យមើល ត្រូវបានអនុម័ត នៅថ្ងៃទី២០ កក្កដា ២០០៥, កឋាខណ្ឌ៧.៣.

23 តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Kuznetsov v. Russia*, អនុវត្តលេខ ១០៨៧៧/០៤, ២៣ តុលា ២០០៨, កឋាខណ្ឌ ៤៤, នឹងគណកម្មការសិទ្ធិមនុស្ស អន្តរអាមេរិក, *របាយការណ៍ ស្តីពីសុន្តិសុខនិងសិទ្ធិមនុស្ស*, កឋាខណ្ឌ១៩៧

៣៤. ការកម្រិតលើ "ពេលវេលា ទីកន្លែង និងរបៀប" គឺនិយាយពីការកម្រិតជាមុន ចំពោះពេលណា ទីកន្លែងណា និងវិធី ដែលការប្រជុំមួយត្រូវធ្វើ។ ការដាក់កម្រិតបែបនេះ មិនគួរមានដាច់ខាត ក្នុងការកំណត់សារ ឬតម្លៃនៃសម្តែងមតិរបស់ការប្រជុំ ឬក្នុងការ បង្អាក់ដល់ការប្រើប្រាស់សិទ្ធិសេរីភាពប្រជុំ។

៣៥. ការទទួលខុសត្រូវក្នុងការធ្វើយុត្តិកម្មអំពីការកម្រិត គឺស្ថិតលើអាជ្ញាធរ។ ប្រសិន ត្រូវដាក់កម្រិត គួរមានជម្រើសសម្រាប់អ្នករៀបចំដើម្បីពិនិត្យផ្នែកតុលាការ និងផ្នែក រដ្ឋបាល ប្រសិនជាប់ពាក់ព័ន្ធ ដោយប្រញាប់ មានសមត្ថភាព ដោយឯករាជ្យ និងមិនលំអៀង[24]។

៣៦. **អនុសាសន៍អនុវត្ត**

(ក) គួរពង្រាងច្បាប់គ្រប់គ្រង អំពីសីលធម៌របស់រដ្ឋឲ្យមានន័យច្បាស់លាស់ ដែលទាក់ទងនឹងការប្រជុំ ហើយគួរបញ្ចូលគ្នា នូវនីត្យានុកូលភាព ការចាំបាច់ និងការធ្វើតេស្តសមាមាត្រ។ ច្បាប់ត្រូវបញ្ជាក់ឲ្យបានច្បាស់ អំពីស្ថាប័នដែលមាន អំណាច និងការទទួលខុសត្រូវ សម្រាប់ទទួលនិងឆ្លើយតបទៅនឹងការជូនដំណឹង។ ដែលស្ថាប័នគួរតែនៅឯករាជ្យ ពីការជ្រៀតជ្រែកហួសហេតុ។ ស្ថាប័ននេះ មិនត្រូវទទួល បានឆន្ទានុសិទ្ធិច្រើនលើសទេះ លក្ខណៈវិនិច្ឆ័យសម្រាប់ការដាក់កំហិត គួរដាក់ឲ្យមានជាសាធារណៈ និងត្រូវអនុលោមទៅតាមបទដ្ឋាន និងច្បាប់អន្តរជាតិ ស្តីពីសិទ្ធិមនុស្ស

(ខ) សំណើរដាក់កំហិត គួរសរសេរជាលាយល័ក្ខណ៍អក្សរ ធ្វើយុត្តិកម្ម ធ្វើទំនាក់ទំនងទៅកាន់អ្នករៀបចំ រួមមានការផ្តល់យុត្តិកម្មចំពោះការដាក់កំហិត ដើម្បីផ្តល់ឱកាសឲ្យអ្នករៀបចំ ក្នុងការដាក់ពាក្យ និងឆ្លើយតបទៅ នឹងសំណើរដាក់កំហិត

(គ) សំណើរដាក់កំហិត គួរទាក់ទង តាមពេលវេលាដែលបានកំណត់ ដោយច្បាប់ ដើម្បីទុកពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ចប់ឧទ្ធរ – ឬការបន្ធូរបន្ថយបណ្តោះ អាសន្ន ជាបន្ទាន់ – ឲ្យបានមុន ពេលវេលាប្រជុំដែលស្នើ

(ឃ) ច្បាប់គួរផ្តល់សិទ្ធិទទួលបានដំណោះស្រាយរដ្ឋបាល។ ទោះយ៉ាងណាក្តី ការប្រើប្រាស់អស់វិធីដំណោះស្រាយរដ្ឋបាល មិនគួរជាតម្រូវការជាមុន សម្រាប់អ្នក រៀបចំ ដើម្បីពិនិត្យផ្នែកតុលាការទេ។

---

[24] សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ២៥/៣៨; សូមមើលផងដែរ A/HRC/20/27, កថាខណ្ឌ៤២

## ឃ. រដ្ឋត្រូវសម្របសម្រួលការប្រើប្រាស់សិទ្ធិប្រជុំដោយសន្តិវិធី

៣៧. រដ្ឋ មានកាតព្វកិច្ចវិជ្ជមាន ដើម្បីធានាសិទ្ធិ ដោយតម្រូវ អាជ្ញាធរ ឲ្យធ្វើការសម្របសម្រួលការប្រជុំ។ រដ្ឋ គួររៀបចំផែនការត្រឹមត្រូវ សម្រាប់ការប្រជុំ តម្រូវឲ្យមានការប្រមូលនិងវិភាគព័ត៌មាន ការប្រមើលទៅលើឆាកផ្សេងៗ និងការធ្វើប្រមាណត្រឹមត្រូវចំពោះហានិភ័យ។ ការធ្វើសម្រេចចិត្តប្រកបដោយតម្លាភាព គឺមានសារៈសំខាន់ក្នុងដំណាក់កាលធ្វើផែនការ និងសម្របសម្រួលការប្រជុំ និងក្នុងការធានាថា រាល់វិធានការដែលចាត់ការដោយមន្ត្រីអនុវត្តច្បាប់ ត្រូវមាន សមាមាត្រនិងចាំបាច់។ត្រូវរៀបចំផែនការសម្រាប់ទប់ទល់ ស្ថានការណ៍អាសន្ន និងវិធានការប្រុងប្រយ័ត្នជាមុន។ ការធ្វើផែនការសម្រាប់ស្ថានភាពគ្រោះអាសន្ន ត្រូវបង្កើតឡើង។ ការធ្វើផែនការ និងការរៀបចំ ដោយត្រឹមត្រូវ ទាមទារឲ្យមានការពិនិត្យតាមដានសកម្មភាពជាបន្ត គួរសម្របទៅ តាមការផ្លាស់ប្តូរកាលៈទេសៈ។

៣៨. កិច្ចការសម្របសម្រួលត្រឹមត្រូវនៃការប្រជុំ ទទួលបានប្រយោជន៍ ទំនាក់ទំនង និងសហការណ៍គ្នាល្អ ចំណោមភាគីពាក់ព័ន្ធទាំងអស់(សូមមើល A/HRC/17/28កឋាខណ្ឌ១១៩)។ កិច្ចសន្ទនាដោយចំហ រវាងអាជ្ញាធរ (រួមមានអាជ្ញាធរទទួលខុសត្រូវក្នុងការទទួលការជូនដំណឹង និងមន្ត្រីអនុវត្តច្បាប់)ជាមួយនឹងអ្នករៀបចំប្រសិនស្គាល់អត្តសញ្ញាណគាត់ មុនពេល អំឡុងពេល និងក្រោយពេលការប្រជុំ គឺផ្តល់នូវវិធីដោះស្រាយកិច្ចពីការការពារនិងសម្រួលសម្រួល ជួយបន្ធូរភាពតានតឹង និងបង្ការការឡើងកំដៅ[25] ។ ភ្នាក់ងារនិងមន្ត្រីអនុវត្តច្បាប់ គួរមានវិធានការទាំងអស់ ដើម្បីទំនាក់ទំនងជាមួយអ្នករៀបចំការប្រជុំ និង/ឬជាមួយអ្នកចូលរួម អំពីប្រតិបត្តិការឈ្លបយកការណ៍និងសុវត្ថិភាព ឬវិធានការសន្តិសុខ[26]។ មិនត្រូវដាក់កំហិត ទៅលើទំនាក់ទំនងតាមសម្តីផ្ទាល់ទេ ហើយមន្ត្រីអនុវត្តច្បាប់ ត្រូវទទួលការបណ្តុះបណ្តាលអំពីផលប៉ះពាល់ដែលអាចកើតមាន ចំពោះទំនាក់ទំនងដោយប្រយោល ដែលអ្នករៀបចំនិងអ្នកចូលរួម គិតថាជាការគំរាមកំហែង ឧទាហរណ៍ វត្តមាននៃការប្រើប្រាស់ឧបករណ៍ខ្លះ និងភាសាកាយវិការបស់មន្ត្រី។

៣៩. ទំនាក់ទំនងដែលប្រសិទ្ធភាព គឺអាស្រ័យលើទំនុកចិត្ត។ ភ្នាក់ងារអនុវត្តច្បាប់ គួរបន្តរៀបចំយុទ្ធសាស្ត្រ ដើម្បីបង្កើតទំនុកចិត្តជាមួយសហគមន៍ ដែលខ្លួនបំរើ។ ភ្នាក់ងារអនុវត្តច្បាប់ ត្រូវមានសមាសភាព តំណាងឲ្យសហគមន៍ទាំងមូល។

---

[25] បណ្ឌិតសភាក្រុងហ្សឺណែវ ស្តីពីច្បាប់អន្តរជាតិមនុស្សធម៌ និងសិទ្ធិមនុស្ស, *សម្របសម្រួលការតវ៉ាដោយសន្តិវិធី* (២០១៤), ទព.១៦

[26] សូមមើល តុលាការសិទ្ធិមនុស្សអឺរ៉ុប, ធ*ប្រ៊ាមគីន v. រុស្ស៊ី*, អនុវត្តលេខ ៧៤៥៦៨/១២, ធ៥ មករា ២០១៦, កឋាខណ្ឌ ១២៧- ១២៨

លំហូព័ត៌មាន គួរប្រព្រឹត្តិទៅដោយសេរី មុនពេលនិងអំឡុងពេលប្រជុំ ហើយភាគីពាក់ព័ន្ធទាំងអស់ គួរជ្រាបជាដំណឹង អំពីការផ្លាស់ប្តូរបរិបទនិងកាលៈទេសៈ។ ទំនាក់ទំនងនិងការសន្ទនា រវាងអ្នករៀបចំនិងអ្នកចូលរួមប្រជុំ ដាច់ខាតត្រូវស្ថិតលើគោលការណ៍ស្ម័គ្រចិត្តទាំងស្រុង ហើយមិនត្រូវចាប់បង្ខំអ្នករៀបចំ ឲ្យជាប់កាតព្វកិច្ចដោយស្របច្បាប់និងមិនស្របច្បាប់ ដើម្បីចចារជាមួយអាជ្ញាធរ អំពីពេលវេលា ទីកន្លែង និងរបៀបប្រជុំ។ ការទាមទារបែបនេះ គឺដូចគ្នាទៅនឹងការដាក់កំហិតមកលើការប្រជុំដែលគ្រោងទុកអញ្ចឹងដែរ (សូមមើលA/HRC/23/39 កឋាខណ្ឌ ៥៦)។

៤០. រដ្ឋមានកាតព្វកិច្ច ក្នុងកិច្ចការសម្របសម្រួល មានដូចជាការទទួលខុសត្រូវផ្តល់សេវាជាមូលដ្ឋាន ការគ្រប់គ្រងចរាចរ ជំនួយពេទ្យ[27] និងសេវាសម្អាត[28]។ មិនត្រូវចាប់បង្ខំអ្នករៀបចំឲ្យទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះទេ ហើយមិនតម្រូវឲ្យពួកគេជួយបង់ថ្លៃសេវាទាំងនោះដែរ។

៤១. មុខងារបឋមក្នុងការអនុវត្តច្បាប់ បន្ថែមពីលើកាតព្វកិច្ចសម្របសម្រួល គឺការការពារសុវត្ថិភាពនិងសិទ្ធិរបស់អ្នកដែលចូលរួមក្នុងការប្រជុំ ព្រមទាំងអ្នកសង្កេតការណ៍និងអ្នកឈរមើល។.

៤២. មន្ត្រីអនុវត្តច្បាប់ ត្រូវទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ស្តីពីការបច្ចេកទេសសម្របសម្រួលការប្រជុំ។ វគ្គបណ្តុះបណ្តាលនេះ គួរបញ្ចូលចំណេះដឹងត្រឹមត្រូវអំពីបទដ្ឋានច្បាប់ដែលគ្រប់គ្រងការប្រជុំ បច្ចេកទេសក្នុងការគ្រប់គ្រងហ្វូងមនុស្ស និងសម្របសម្រួល សិទ្ធិមនុស្សក្នុងបរិបទនៃការប្រជុំ និងតួនាទីសំខាន់នៃការប្រជុំដែលមាននៅក្នុងលំដាប់ប្រជាធិបតេយ្យ។ ការបណ្តុះបណ្តាល ត្រូវបញ្ចូលជំនាញ "ទន់" ដូចជាទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ការចចារ និងសម្រុះសម្រួល ដល់មន្ត្រីអនុវត្តច្បាប់ ដើម្បីបញ្ចៀសការឡើងកំដៅនៃអំពើហិង្សា និងកាត់បន្ថយជម្លោះ[29]

៤៣. ការប្រប្រាស់វិធី "ឈប់ត្រួតពិនិត្យ"របស់មន្ត្រីអនុវត្តច្បាប់ មកលើបុគ្គលដែលរៀបចំនិងចូលរួមក្នុងការប្រជុំ អាចបង្កឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងសន្តិសុខរាងកាយព្រមទាំងជីវិតឯកជន។ ការឈប់ត្រួតពិនិត្យ មិនត្រូវធ្វើតាមអំពើចិត្តទេ និងមិនត្រូវរំលោភលើគោលការណ៍មិនរើសអើង។ ត្រូវមានច្បាប់អនុញ្ញាត ជាចាំបាច់

---

[27] សូមមើលគោលការណ៍៥ នៃគោលការណ៍ជាមូលដ្ឋាន ស្តីពីការប្រើប្រាស់កម្លាំង និងអាវុធដោយមន្ត្រីអនុវត្តច្បាប់

[28] OSCE/ODIHR,គោលការណ៍ណែនាំ, កឋាខណ្ឌ ៣២

[29] សូមមើលគោលការណ៍ណែនាំ ២០ នៃគោលការណ៍មូលដ្ឋានគ្រឹះ, និង OSCE/ODIHR, *គោលការណ៍ណែនាំ កឋាខណ្ឌ ១៤៧*

និងតាមសមាមាត្រ[30] ។ ប្រការដែលថា បុគ្គលម្នាក់គ្រាន់តែចូលរួម ការប្រជុំសន្តិវិធីមួយ មិនត្រូវបង្កើតជាមូលដ្ឋានសមហេតុផល សម្រាប់ធ្វើការឆែកឆេរទេ។

៩៤. អំណាចធ្វើការឃាត់ខ្លួន អាចបំពេញមុខងារការពារសំខាន់ នៅក្នុងការប្រជុំ ដោយអនុញ្ញាតមន្ត្រីអនុវត្តច្បាប់ ឲ្យដកបុគ្គលដែលកំពុងប្រព្រឹត្តិហិង្សា ចេញពីការប្រជុំ។ ពាក្យ "ចាប់" មានន័យចំពោះ ការដកហូតសេរីភាព ហើយវាមិនកំណត់ ទៅលើការចាប់ខ្លួនតាមផ្លូវការទេ យោងតាមច្បាប់ក្នុងស្រុក។ វាសំខាន់ដែលថាការប្រើប្រាស់ អំណាចចាប់ខ្លួន ត្រូវប្រើប្រាស់ឲ្យស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីសិទ្ធិមនុស្ស រួមទាំង សិទ្ធិជីវិតឯកជន សេរីភាព និងសិទ្ធិនៃដំណើរការទៅតាមដំណើរការស្របតាមផ្លូវច្បាប់។

៩៥. គ្មានបុគ្គលណាម្នាក់ រងការចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តទេ។ នៅក្នុងបរិបទ ការប្រជុំ ត្រង់នេះមានអត្ថន័យពិសេស ដែលការប្រជុំនិងអ្នកប្រឆាំងក្លាយ ជាបទឧក្រិដ្ឋ។ ការចាប់អ្នកតវ៉ា ដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មពួកគេមិនឲ្យប្រើប្រាស់សិទ្ធិរបស់ខ្លួន ចំពោះសេរីភាពនៃការប្រជុំដោយសន្តិវិធី អាចរំលោភការការពារទាំងនេះ ឧទាហរណ៍ បទចោតប្រកាន់ដែលមិនត្រឹមត្រូវ គ្មានហេតុផល ឬខ្វះសមាមាត្រ។ ស្រដៀងគ្នានេះដែរ វិធានការដែលរំលោភបំពាននិងធ្វើឲ្យចុះខ្សោយជាមុន មិនត្រូវយកមកប្រើទេ លុះត្រាតែ គ្រោះថ្នាក់នៃអំពើហិង្សាបង្ហាញច្បាស់ ដែលរៀបនឹងកើតឡើងពិតប្រាកដ។ "ការចាប់ខ្លួនជាហ្វូង" នៃអ្នកចូលរួមការប្រជុំ ជាញឹកញាប់ សន្មត់ថាជាការចាប់ខ្លួន តាមអំពើចិត្តនិងមិនរើសមុខ។

៩៦. ប្រសិនការចាប់ខ្លួនកើតឡើង ល័ក្ខខ័ណ្ឌឃុំឃាំង ត្រូវតែអនុវត្តតាមបទដ្ឋាន អប្បរិមា។ចំណុចនេះទាក់ទងនឹងទីតាំងឬស្ថានភាព ដែលបុគ្គលត្រូវបានដកហូត សេរីភាពរបស់ខ្លួន រួមមានពន្ធនាគារ ទីឃុំឃាំង ទីសាធារណៈ និងយានយន្ត ប្រើសម្រាប់ផ្ទេរអ្នកជាប់ឃុំ និងទីតាំងដទៃទៀត ដែលអ្នកជាប់ឃុំ ត្រូវបានដាក់។ ត្រូវប្រព្រឹត្តិមកលើអ្នកជាប់ឃុំ តាមរបៀបមនុស្សធម៌ និងមានការគោរពភាពថ្លៃថ្នូរ[31] របស់ពួកគេ និងមិនត្រូវរងអំពីទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

30 ក្រុមការងារ ស្តីពីការការពារសិទ្ធិមនុស្ស ខណៈដែលប្រឆាំងនឹងអំពើភេរវកម្ម, *គោលការណ៍ណែនាំមូលដ្ឋានគ្រឹះស្តីពីសិទ្ធិមនុស្ស: បញ្ឈប់ និងការស្វែងរកមនុស្ស (កញ្ញា ២០១០).*

31 គោលការណ៍ ១ស្ថាប័នគោលការណ៍ សម្រាប់ការការពារបុគ្គលគ្រប់រូប នៅក្នុងទម្រង់ឃុំឃាំង ឬជាប់ពន្ធនាគារ

៩៧. ការបង្ខិតបង្ខំក្នុងការដាក់ឃុំឃាំងរដ្ឋបាល គឺមានបញ្ហា។ គណៈកម្មការសិទ្ធិមនុស្ស ធ្លាប់បានបញ្ជាក់ថាការឃុំឃាំងបែបនោះផ្តល់ហានិភ័យធ្ងន់ធ្ងរចំពោះការដកហូត សេរីភាព[32] តាមអំពើចិត្តដោយមិនគិតពីការកាត់ទោសបទឧក្រិដ្ឋផង។

៩៨. ការប្រើប្រាស់សមាមាត្រជាពិសេស ទាក់ទងទៅនឹងការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល នៅក្នុងបរិបទការប្រជុំ។ ការពិន័យណាមួយនោះ មិនត្រូវធ្វើឲ្យហួសហេតុពេកទេ ឧទាហរណ៍ ការពិន័យប្រាក់យ៉ាងច្រើនបំផុត។ ការពិន័យប្រាក់បែបនេះ អាចបង្កើនក្តីព្រួយបារម្ភអំពីដំណើរការផ្លូវច្បាប់និងអាចមានឥទ្ធិពលកាន់តែភ័យខ្លាចខ្លាំង ទៅលើការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការប្រជុំដោយសន្តិវិធី

៩៩. **អនុសាសន៍អនុវត្ត ៖**

(ក) រដ្ឋ គួរតែលើកស្ទួយ ការអនុវត្តច្បាប់ចម្រុះ ដើម្បីឲ្យសហគមន៍មើលឃើញខ្លួនឯងថាបានចូលរួមសហការជាមួយប៉ូលិស។ នេះទាមទារនូវស្ថាប័នតំណាង ដែលមានការចូលរួមរបស់ស្ត្រីនិងក្រុមសម្លេងតិច

(ខ) រដ្ឋ គួរអនុវត្តវិធីសាស្ត្រធ្វើផែនការដូចៗគ្នា សម្រាប់ការប្រជុំទាំងអស់ ទៅតាមគំរូដោយផ្អែកលើការធ្វើប្រមាណអំពីការគំរាមកំហែងនិងហានិភ័យ និងបញ្ចូល បទដ្ឋាននិងច្បាប់សិទ្ធិមនុស្ស ព្រមទាំងសីលធម៌។

(គ) អាជ្ញាធរសាធារណៈ រួមទាំងមន្ត្រីអនុវត្តច្បាប់ ត្រូវមានសមត្ថភាព បង្ហាញភស្តុតាងនូវការព្យាយាមរបស់ខ្លួនដើម្បីរួមប្រាស្រ័យទាក់ទងដោយសុទ្ធចិត្ត ជាមួយអ្នករៀបចំការប្រជុំ និង/ឬអ្នកចូលរួមការប្រជុំ

(ឃ) ភ្នាក់ងារអនុវត្តច្បាប់ គួរធានាថាមានអង្គភាពទំនាក់ទំនងដែលជាច្រក ទំនាក់ទំនងដែលអាចចេញចូលបាន មុនពេល អំឡុងពេល និងក្រោយពេលការប្រជុំ។ អង្គភាពទំនាក់ទំនង គួរទទួលបានការបណ្តុះបណ្តាល នូវជំនាញទំនាក់ទំនងនិង ការគ្រប់គ្រងជម្លោះ និងឆ្លើយតបទៅនឹងបញ្ហាសន្តិសុខ និងក្រមសីលធម៌របស់នគរបាល ព្រមទាំងឆ្លើយតបទៅនឹងការទាមទារយ៉ាងច្រើន និងទស្សនៈដែលបានសម្តែងចេញ ដោយអ្នកចូលរួមការប្រជុំ។ មុខងារទំនាក់ទំនង គួរចែកឲ្យដាច់ពីមុខងារឈ្លបយកការណ៍ដទៃទៀត

[32] សូមមើលអត្ថាធិប្បាយទូទៅរបស់គណកម្មាធិការ លេខ ៣៥ (២០១៤) ស្តីពីសេរីភាព និងសន្តិសុខរបស់បុគ្គល, កថាខណ្ឌ ១៥

(ង) រដ្ឋ និងស្ថាប័នអនុវត្តច្បាប់ គួរធានាបង្កើតយន្តការជាអចិន្ត្រៃយ៍ សម្រាប់វាយតម្លៃសភាពការក្រោយពេលប្រជុំ ដើម្បីដកពិសោធន៍ ជាមេរៀននិងធានាការការពារសិទ្ធិ

(ច) ស្ថាប័នអនុវត្តច្បាប់ គួរសហការជាមួយអ្នកបម្រើការ ដែលអ្នកចាត់ចែងបានជ្រើសរើសពួកគេ ឲ្យជួយបម្រើដល់ការប្រជុំ។ អ្នកបម្រើការប្រជុំ គួរបង្ហាញអត្តសញ្ញាណច្បាស់ និងគួរទទួលការបណ្តុះបណ្តាលត្រឹមត្រូវនិង ទទួលព័ត៌មានសង្ខេបស្តីពីការប្រជុំជាមុន។អាជ្ញាធរមិនគួរ តម្រូវឲ្យអ្នករៀបចំផ្តល់អ្នកបម្រើការទេ។

(ឆ) វិធានការរំខាន មិនគួរប្រើនៅក្នុងការប្រជុំទេ។ ត្រូវបញ្ឈប់ការឆែកឆេរ ឬចាប់ខ្លួនអ្នកចូលរួមដែលធ្វើដំណើរចូលរួមកប្រជុំទេ លុះត្រាតែមាន គ្រោះថ្នាក់ពីអំពើហិង្សាដែលជិតកើតឡើង បង្ហាញវត្តមានច្បាស់លាស់

## ខ. មិនត្រូវប្រើកម្លាំងដាច់ខាត លុះត្រាតែមិនអាចជៀសបាន ហើយប្រសិនប្រើនោះ គួរតែអនុវត្តតាមច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស

៥០. រដ្ឋ និងភ្នាក់ងារនិងមន្រ្តីអនុវត្តច្បាប់របស់ខ្លួន ត្រូវជាប់កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ដើម្បីគោរពនិងការពារ ដោយគ្មានការរើសអើង ចំពោះសិទ្ធិរបស់អ្នកទាំងឡាយដែលចូលរួមក្នុងការប្រជុំ ព្រមទាំងសិទ្ធិរបស់អ្នកសង្កេតការណ៍ និង អ្នកឈរមើល[33] ។ ប្រព័ន្ធគំរូត្រឹមត្រូវ រួមមាន គោលការណ៍នីត្យានុកូលភាព វិធានការប្រុងប្រយ័ត្នជាមុន សមាមាត្រ និងការទទួលខុសត្រូវ។

៥១. គោលការណ៍នីត្យានុកូលភាព តម្រូវឲ្យរដ្ឋអភិវឌ្ឍនូវគម្រោងច្បាប់ក្នុងស្រុកមួយ សម្រាប់ការប្រើប្រាស់កម្លាំង ជាពិសេសកម្លាំងដែលប្រល័យជីវិត ដោយអនុវត្តតាមបទដ្ឋានអន្តរជាតិ (សូមមើលA/HRC/26/36 កឋាខណ្ឌ៥៦)។ ប្រព័ន្ធគំរូត្រឹមត្រូវ ជាពិសេសគួរតែដាក់កំហិត លើការប្រើប្រាស់អាវុធនិងកលល្បិច អំឡុងពេលប្រជុំ រួមទាំងការតវ៉ា និងការយល់ព្រមតាមផ្លូវការ និងការពង្រាយអាវុធនិងឧបករណ៍[34]។

៥២. គោលការណ៍ប្រុងប្រយ័ត្នជាមុន តម្រូវឲ្យប្រកាន់យកវិធានការទាំងអស់ដែលអាចធ្វើទៅបាន ដើម្បីធ្វើផែនការ រៀបចំ និងបំពេញបេសកកម្ម ដែលទាក់ទងនឹង

[33] ក្រមរបស់មន្រ្តីអនុវត្តច្បាប់ ត្រូវបានគ្រប់គ្រង ក្នុងចំណោមរឿងផ្សេងៗ ដោយច្បាប់សិទ្ធិមនុស្ស។ ក្រមសីលធម៌សម្រាប់មន្ត្រីអនុវត្តច្បាប់ និងគោលការណ៍គ្រឹះ ស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ ដោយមន្ត្រីអនុវត្តច្បាប់។ សូមមើលផងដែរ អំពីគោលការណ៍ ស្តីពីការបង្ការប្រសិទ្ធភាព និងស៊ើបអង្កេត នៃការសម្លាប់ភ្លាមៗ ឬតាមអំពើចិត្ត ក្រៅច្បាប់។

[34] សូមមើល, ឧទាហរណ៍, អង្គការលើកលែងទោសអន្តរជាតិ, *ការប្រើប្រាស់កម្លាំង: គោលការណ៍ណែនាំ សម្រាប់អនុវត្តនូវគោលការណ៍គ្រឹះរបស់អង្គការសហប្រជាជាតិ ស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ ដោយមន្ត្រីអនុវត្តច្បាប់ (២០០៥)*, ទព. ៤៦

ការប្រជុំ ដើម្បីជៀសវាងការប្រើប្រាស់កម្លាំង ឬប្រសិនមិនអាចជៀសពីការប្រើកម្លាំងបាន ដើម្បីបន្ថយផលវិបាកគ្រោះថ្នាក់។ បើទោះជាត្រូវប្រើកម្លាំង នៅក្នុងស្ថានភាពពិសេស ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌទាមទារជាចាំបាច់ និងសមាមាត្រ ប៉ុន្តែតម្រូវការចាំបាច់ប្រើប្រាស់កម្លាំងអាចត្រូវបានទប់ស្កាត់ដោយសមហេតុផលតាំងពីគ្រាដំបូង។ រដ្ឋមួយអាចចាប់បង្ខំឲ្យទទួលខុសត្រូវចំពោះការខកខានក្នុងការចាត់វិធានការទាន់ពេលដោយប្រុងប្រយ័ត្ន[35] ។ ការបណ្ដុះ គួរបញ្ចូលបច្ចេកទេស នៃការសម្រួលនិងគ្រប់គ្រងហ្វូងមនុស្ស ជាមួយនឹងប្រព័ន្ធច្បាប់គ្រប់គ្រងការប្រជុំ[36] ។ រដ្ឋត្រូវធានាថា មន្ត្រីអនុវត្តច្បាប់របស់ខ្លួនទទួលបានការបណ្ដុះបណ្ដាលតាមវេលាកំណត់ និងសាកល្បងអំពីការប្រើប្រាស់ អាវុធដែលពួកគេបានបំពាក់ដោយស្របច្បាប់[37]

៥៣. ដោយឈរលើមូលដ្ឋាន ការធ្វើប្រមាណអំពីហានិភ័យ ឧបករណ៍សម្រាប់កម្លាំងមន្ត្រីអនុវត្តច្បាប់ដែលបានពង្រាយ ក្នុងអំឡុងពេលប្រជុំ គួររាប់បញ្ចូល ឧបករណ៍ការពារខ្លួនត្រឹមត្រូវ និងជម្រើសអាវុធដែលសមស្របមិនសូវបង្កគ្រោះថ្នាក់ ដល់ជីវិត[38] ។ អាវុធនិងកលល្បិច គួរអនុញ្ញាតសម្រាប់ឆ្លើយតប និងសម្រាប់បន្ទូរភាពតានតឹងដោយដាច់ពីគ្នា ។ ដូច្នេះ ការផ្ដល់អាវុធដល់មន្ត្រីអនុវត្តច្បាប់ដែលមិនមែនជាអាវុធប្រភេទដែលមិនសូវបង្កគ្រោះថ្នាក់ជីវិតដូចជាដំបង គឺមិនអាចទទួលយកបានទេ។

៥៤. បើចាំបាច់ មន្ត្រីត្រូវប្រើប្រាស់ឧបករណ៍ការពារខ្លួន ដូចជាខែល មួកសុវត្ថិភាព និងអាវការពារគ្រាប់កាំភ្លើងឬ/និងការពារការកាប់ចាក់ដើម្បីកាត់បន្ថយតម្រូវការប្រើប្រាស់អាវុធ របស់មន្ត្រីអនុវត្តច្បាប់។ មិនត្រូវអនុញ្ញាត[39]ឲ្យប្រើប្រាស់អាវុធទេដោយសារអាវុធទាំងនោះមិនធ្វើឲ្យសម្រេចបំណង ក្នុងការពង្រឹងច្បាប់ដោយស្របច្បាប់ ដែលមិនចង់នាំឲ្យមានហានិភ័យ ជាពិសេសក្នុងកាលៈទេសៈនៃការប្រជុំមួយ

៥៥. រដ្ឋត្រូវផ្គត់ផ្គង់អាវុធណាដែលមិនសូវបង្កគ្រោះថ្នាក់ដល់ជីវិត សម្រាប់ប្រើប្រាស់នៅក្នុងស្ថានភាពសមស្របដែលមើលឃើញអំពីការជំរុញទប់ស្កាត់ការលើការអនុវត្តមធ្យោបាយណាដែលអាចបង្កការស្លាប់ ឬ របួសស្នាម[40] ។ អាវុធដែលមិនសូវគ្រោះថ្នាក់

---

[35] តុលាការសិទ្ធិមនុស្សអឺរ៉ុប, *ម៉ាកេន និងអ្នកដទៃទៀត v. ចក្រភពអង់គ្លេស*, អនុវត្ត លេខ ១៨៩៨៤/៩១, ២៧ កញ្ញា ១៩៩៥

[36] គោលការណ៍ ២០ នៃគោលការណ៍មូលដ្ឋានគ្រឹះ,និង OSCE/ODIHR, *គោលការណ៍ណែនាំ*, កឋាខណ្ឌ ១៥៧

[37] គោលការណ៍១៩ នៃគោលការណ៍មូលដ្ឋានគ្រឹះ

[38] គោលការណ៍២ នៃគោលការណ៍មូលដ្ឋានគ្រឹះ។ អាវុធដែលមិនសូវគ្រោះថ្នាក់ដល់ជីវិត អាចមានផលវិបាកដល់អាយុជីវិត ឬប៉ះពាល់មកលើអ្នកឈរមើល (សូមមើល គោលការណ៍ ៣នៃគោលការណ៍មូលដ្ឋានគ្រឹះ)

[39] សូមមើល អង្គការលើកលែងទោសអន្តរជាតិ, *គោលការណ៍ស្ដីពីការប្រើប្រាស់កម្លាំង*, វគ្គ៦

[40] Ibid.

ដល់ជីវិតត្រូវឆ្លងកាត់ការយល់ព្រម និង ធ្វើតេស្តតាមវិទ្យាសាស្ត្រ និងប្រើប្រាស់ដោយទទួលខុសត្រូវ ដោយមន្ត្រីដែលឆ្លងកាត់ការហ្វឹកហ្វឺនត្រឹមត្រូវ ពីព្រោះអាវុធប្រភេទនោះអាចមានឥទ្ធិពលដល់ស្លាប់ឬរបួស ប្រសិនមិនប្រើឲ្យបានត្រឹមត្រូវ ឬទៅតាមបទដ្ឋាន និងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ រដ្ឋគួរបង្កើតនិងអនុវត្តពិធីសារអន្តរជាតិសម្រាប់បណ្តុះបណ្តាលអំពីការប្រើ ប្រាស់អាវុធដែលមិនសូវគ្រោះថ្នាក់ដល់ស្លាប់។

៥៦. កំណើនប្រភេទអាវុធដែលអាចបញ្ជាពីចម្ងាយ គឺអាចរកបាន ជាពិសេសក្នុងបរិបទការឈ្លបយកការណ៍ពីការប្រជុំ។ ត្រូវប្រុងប្រយ័ត្នបំផុត ចំពោះបញ្ហានេះ។ ប្រសិនបច្ចេកវិទ្យាទំនើប ត្រូវបានប្រើប្រាស់ មន្ត្រីអនុវត្តច្បាប់ ត្រូវតែគ្រប់គ្រងខ្លួនឯងគ្រប់ពេលវេលា នៅពេលបង្រាយឬបញ្ចេញកម្លាំង (សូនមើល A/69/265កឋាខណ្ឌ ៧៧-៨៧)[41]

៥៧. ការប្រើប្រាស់កម្លាំងដោយមន្ត្រីអនុវត្តច្បាប់ គួរតែជាករណីពិសេស[42] ហើយការប្រជុំ គួរតែប្រព្រឹត្តទៅតាមធម្មតា ដោយមិនជ្រើសរើសយកកម្លាំងបាយ។ ការប្រើកម្លាំងណាមួយ ត្រូវតែអនុវត្តទៅតាមគោលការណ៍ចាំបាច់ និងសមាមាត្រ។ តម្រូវការចាំបាច់ ដាក់កំហិតលើការប្រើប្រាស់កម្លាំងគ្រប់ប្រភេទ និងគ្រប់កំរិតជាអប្បរិមាបើចាំបាច់ នៅក្នុងកាលៈទេសៈ(មធ្យោបាយគ្រោះថ្នាក់តិចតួចបំផុត) ដែលជាការធ្វើប្រមាណអំពីបុព្វហេតុនិងផលប៉ះពាល់ពិតប្រកដ។ ការប្រើប្រាស់កម្លាំង គួរផ្តោតលើបុគ្គលដែលប្រើអំពើហិង្សា ឬ ប្រើសម្រាប់បញ្ចៀសការគំរាមកំហែងដែលជិតកើតឡើង។

៥៨. តម្រូវការសមាមាត្រ គឺកំរិតលើការប្រើកម្លាំង ដោយផ្អែកលើការកំរាមកំហែងរបស់បុគ្គលគោលដៅ។ នេះជាការវាយតំលៃអំពីប្រយោជន៍ ថ្លឹងថ្លែងអំពីគ្រោះថ្នាក់និងផលប្រយោជន៍ ដោយទាមទារថា គ្រោះថ្នាក់អាចបណ្តាលមកពីការប្រើប្រាស់កម្លាំងគឺសមាមាត្រ និងធ្វើយុត្តិកម្ម ដែលទាក់ទងទៅនឹងប្រយោជន៍ដែលរំពឹងទុក។

៥៩. គោលការណ៍តម្រូវការចាំបាច់និងសាមាមាត្រ
គឺអនុវត្តចំពោះការប្រើប្រាស់ទាំងអស់ រួមទាំងកម្លាំងប្រល័យជីវិត ។ មានវិន័យជាក់លាក់ទាក់ទងទៅនឹងការប្រើអាវុធសម្រាប់ការអនុវត្តច្បាប់ និងអំឡុងពេល ប្រជុំផងដែរ[43] ។ អាវុធ អាចប្រើប្រាស់សម្រាប់ប្រឆាំងតែការគំរាមកំហែង ដែលជិត កើតឡើង

---

41 សូមមើលគណកម្មការអាហ្វ្រិក ស្តីពីសិទ្ធិប្រជាជន និងសិទ្ធិមនុស្ស, ឯអត្ថាធិប្បាយទូទៅ លេខ ៣ (២០១៥) ស្តីពីធម្មនុញ្ញអាហ្វ្រិក ស្ដីពីសិទ្ធិប្រជាជន និងសិទ្ធិមនុស្ស : សិទ្ធិរស់រានមានជីវិត (មាត្រា៤), កឋាខណ្ឌ ៣១

42 សូមមើល បទអត្ថាធិប្បាយ ទៅលើមាត្រា៣ នៃក្រមសីលធម៌ សម្រាប់មន្ត្រីអនុវត្តច្បាប់

43 គោលការណ៍ ៩ នៃគោលការណ៍មូលដ្ឋានគ្រឹះ

ដើម្បីការពារជីវិត ឬបង្ការរបួសស្នាមដែលគំរាមកំហែងដល់ជីវិត (អនុវត្តការប្រើកម្លាំងសមាមាត្រ)។ ពុំមានជម្រើសបន្ថែមអ្វីផ្សេងទៀតទេ ដូចជាការចាប់ខ្លួន ឬការប្រើកម្លាំងមិនប្រល័យជីវិត ដើម្បីដោះស្រាយការកំរាមកំហែងជីវិត (អនុវត្តកម្លាំងដែលចាំបាច់)

៦០. មិនត្រូវប្រើអាវុធដោយងាយ ដើម្បីបំបែកការប្រជុំ។ ការបាញ់មិនរើសមុខទៅលើហ្វូងមនុស្ស គឺជារឿងខុសច្បាប់ជាដរាប(សូមមើលA/HRC/26/36កឋាខណ្ឌ៧៥)។ ការប៉ុនប៉ងប្រើប្រាស់កម្លាំងប្រល័យជីវិត ត្រូវស្របតាមច្បាប់ប៉ុណ្ណោះ ប្រសិនមិនអាចជៀសវាងបានដាច់ខាត ដើម្បីការពារជីវិតមួយទៀតពីការ គំរាមកំហែងដែលជិតកើតឡើង។ ចំណុចនេះ នៅពេលខ្លះគឺនិយាយដល់គោលការណ៍ ការពារជីវិត(ibid., កឋាខណ្ឌ៧០)

៦១. ការបំបែកការប្រជុំមួយ មានហានិភ័យនៃការរំលោភសិទ្ធិសេរីភាពសម្តែងមតិ និងការប្រជុំដោយសន្តិវិធី ព្រមទាំងសិទ្ធិបូរណភាពរាងកាយ។ ការបំបែកការប្រជុំមួយ មានហានិភ័យបង្កើនភាពតានតឹងរវាងអ្នកចូលរួមនិងមន្ត្រីអនុវត្តច្បាប់ផងដែរ។ ដោយសារហេតុផលទាំងអស់នេះហើយ ការបំបែកត្រូវតែជាជំរើសចុងក្រោយ ប៉ុណ្ណោះ នៅពេលដែលមិនអាចជៀសបាន។ ឧទាហរណ៍ គេគួរពិចារណាការបំបែក ប្រសិន អំពើហិង្សា មានសភាពធ្ងន់ធ្ងរ និងរីករាលដាល និងបង្កគំរាមកំហែងដែលជិតកើតឡើង ចំពោះសុវត្ថិភាពរាងកាយ ឬទ្រព្យសម្បត្តិ និងប្រសិនមន្ត្រីអនុវត្តច្បាប់ បានចាត់វាល់វិធានការសមហេតុផល ដើម្បីសម្រួលដល់ការប្រជុំនិងការពារអ្នកចូលរួម ពីគ្រោះថ្នាក់។ មុនអនុញ្ញាតការបំបែក ភ្នាក់ងារអនុវត្តច្បាប់ គួរតែកំនត់អត្តសញ្ញាណ បុគ្គលដែលបង្កហិង្សា និងបំបែកបុគ្គលទាំងនោះចេញពីការប្រជុំ និងបែកចែកឲ្យ ដាច់រវាងបុគ្គលដែលប្រើហិង្សា និងបុគ្គលផ្សេងៗ ដែលចូលរួមក្នុងការប្រជុំ។ វិធីនេះ គឺទុកឲ្យការប្រជុំបន្ត

៦២. ច្បាប់អន្តរជាតិ អនុញ្ញាតឲ្យបំបែកការប្រជុំដោយសន្តិវិធី ក្នុងករណីពិសេស ប៉ុណ្ណោះ។ ឧទាហរណ៍ ការប្រជុំដោយសន្តិវិធី ដែលញុះញង់ការរើសអើង អរិយភាព ឬអំពើហិង្សា ដែលជាការបំពាន នៅក្នុងមាត្រា២០នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ប្រហែលចាំបាច់ត្រូវការបំបែក ប្រសិនបើមធ្យោបាយ ដែលរំលោភតិច និងរើសអើង នៅក្នុងការគ្រប់គ្រងស្ថានភាព ទទួលបរាជ័យ។ ស្រដៀងគ្នានេះដែរ ការបង្កការលំបាកដល់អ្នកអ្នកដទៃ ឬការរំខានបណ្តោះអាសន្ន ដល់ចរាចរយានយន្តឬអ្នកដំណើរ គួរត្រូវបានអត់អោន ប្រសិនការប្រជុំមួយ បង្កភាពរាំងស្ទះផ្លូវចេញចូល ដើម្បីទទួលសេវាសំខាន់ៗ ដូចជាការបិទច្រក ផ្លូវសង្គ្រោះ

បន្ទាន់ ទៅកាន់មន្ទីរពេទ្យ ឬប្រសិនការជ្រៀតជ្រែកនឹងចរាចរឬសេដ្ឋកិច្ច មានសភាពធ្ងន់ធ្ងរ និងយូរអង្វែង ឧទាហរណ៍ ផ្លូវស្ពានអាកាសសំខាន់ៗ ត្រូវបានបិទស្ទះជាច្រើនថ្ងៃ ការបំបែកអាចត្រូវបានធ្វើយុត្តិកម្មបាន។ ការខកខានមិនបានផ្តល់ដំណឹងអំពីការប្រជុំដល់អាជ្ញាធរ មិនមែនជាមូលដ្ឋានសម្រាប់បំបែកឡើយ។

៦៣. អាជ្ញាធររដ្ឋាភិបាល ឬមន្ត្រីជាន់ខ្ពស់ ដែលមានព័ត៌មានសុក្រិតនិងគ្រប់គ្រាន់អំពីស្ថានភាពដែលត្រដាងក្នុងចំណោមសាធារណៈជនទូទៅ គួរមានអំណាចបញ្ជាការបំបែក។ ប្រសិនការបំបែកចាំបាច់ គួរជម្រាបដល់ការប្រជុំនិងអ្នកចូលរួមឲ្យបានដឹងឮច្បាស់ និងទុកពេលវេលាគ្រប់គ្រាន់ ដើម្បីបំបែកដោយស្ម័គ្រចិត្ត[44] ។ ហើយប្រសិនអ្នកចូលរួម មិនព្រមបំបែក មន្ត្រីអនុវត្តច្បាប់ ធ្វើអន្តរាគមបន្ថែម

៦៤. ជាផ្នែកមួយនៃការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាគណនីយភាព រដ្ឋត្រូវបង្កើតវិធានពិនិត្យឡើងវិញ និងធ្វើរបាយការណ៍ប្រសិទ្ធភាព ដើម្បីដោះស្រាយឧប្បត្តិហេតុមួយ ដែលទាក់ទងនឹងការប្រជុំ អំឡុងពេល ដែលការប្រើប្រាស់កម្លាំងខុសច្បាប់កើតឡើង[45]

៦៥. ត្រូវបង្កើតឡើង រចនាសម្ព័ន្ធបញ្ជាច្បាស់លាស់និងប្រកបដោយតម្លាភាព ដើម្បីបន្ថយការប្រឈមអំពើហិង្សា ឬការប្រើកម្លាំង និងដើម្បីធានាការទទួលខុសត្រូវចំពោះអំពើល្មើសច្បាប់ ឬ ការភ្លេចភ្លាំងរបស់ដោយមន្ត្រី[46] ។ ការរក្សាកំណត់ត្រាត្រឹមត្រូវអំពីសេចក្តីសម្រេចចិត្តរបស់មន្ត្រីបញ្ជាការនៅគ្រប់ជាន់ថ្នាក់ទាំងអស់ គឺត្រូវការចាំបាច់។ មន្ត្រីអនុវត្តច្បាប់ ត្រូវស្គាល់អត្តសញ្ញាណច្បាស់លាស់ ឧទាហរណ៍ ត្រូវពាក់ផ្លាកឈ្មោះឬអត្តលេខ ឲ្យបានគ្រប់គ្នា។ លើសពីនេះ គួរមានប្រព័ន្ធកត់ត្រាមួយច្បាស់លាស់ ឬការកត់ត្រាឧបករណ៍ ដែលបានផ្តល់ឲ្យមន្ត្រីម្នាក់ៗ ក្នុងពេលចេញប្រតិបត្តិការ រួមមានយានយន្ត កាំភ្លើងនិងគ្រាប់រំសេវ

៦៦. យោងតាមវិន័យទូទៅ មិនគួរប្រើកម្លាំងយោធា ដើម្បីតាមដានឈ្លបយកការណ៍ពីការប្រជុំទេ។ ក្នុង កាលៈទេសៈពិសេស បើចាំបាច់ យោធាត្រូវស្ថិតក្រោមការបង្គាប់រដ្ឋអំណាចស៊ីវិល[47] ។ យោធាត្រូវទទួលបានការហ្វឹកហ្វឺនពេញលេញផងដែរ ត្រូវអនុវត្តនិងត្រូវជាប់កាតព្វកិច្ច នៃគោលការណ៍ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សព្រមទាំងគោលនយោបាយអនុវត្តច្បាប់ គោលការណ៍ណែនាំ សីលធម៌ និងទទួលការបណ្តុះបណ្តាល

[44] សូមមើល OSCE/ODIHR, *គោលការណ៍ណែនាំ*, កឋាខណ្ឌ១៦៨.
[45] គោលការណ៍ណែនាំ ២២ នៃគោលការណ៍ណែនាំមូលដ្ឋានគ្រឹះ, និងមាត្រា ៨, ដោយមានបទអត្ថាធិប្បាយនូវក្រមសីលធម៌
[46] គោលការណ៍ណែនាំ ២៤-២៦ នៃ គោលការណ៍ណែនាំគ្រឹះ
[47] បទអត្ថាធិប្បាយ ចំពោះមាត្រា ១ នៃក្រមសីលធម៌

ផ្សេងៗទៀត និងទទួលឧបករណ៍ដែលចាំបាច់។ ដើម្បីអនុវត្តការតម្រូវការទាំងនេះ រដ្ឋត្រូវដាក់វិធានការ ពីចម្ងាយជាមុន ដោយស្ថានភាពបែបនោះកើតឡើងពេលក្រោយ។

៦៧. **អនុសាសន៍អនុវត្តះ**

(ក) រដ្ឋគួរធានាថា មន្ត្រីអនុវត្តច្បាប់ មានឧបករណ៍ មានការបណ្តុះបណ្តាល និងទទួលបានការណែនាំជាចាំបាច់ ដើម្បីឈ្លបយកការណ៍នៃការប្រជុំ បើសិនលទ្ធភាពមាន ដោយគ្មានការប្រើប្រាស់កម្លាំងជំនួយ

(ខ) កលល្បិចក្នុងការឈ្លបយកការណ៍ពីការប្រជុំ គួរតែសង្កត់ទៅលើកលល្បិចបន្ធូរបន្ថយកំណើនហិង្សា ដោយឈរលើមូលដ្ឋានទំនាក់ទំនង ការចចារ និងការប្រាស្រ័យទាក់ទង។ ការបណ្តុះបណ្តាលរបស់មន្ត្រីអនុវត្តច្បាប់ គួរបញ្ចូលការណែនាំ នៅមុនពេលនិងក្នុងពេលបំពេញការងារ ទាំងនៅក្នុងថ្នាក់រៀននិងនៅទីកន្លែងការងារជាក់ស្តែង

(គ) មុនពេលជ្រើសរើស និងចែកចាយឧបករណ៍ភ្នាក់ងារអនុវត្តច្បាប់ រួមមានអាវុធដែលមិនសូវបង្ក គ្រោះថ្នាក់ដល់ជីវិត សម្រាប់ប្រើប្រាស់ក្នុងពេលប្រជុំ រដ្ឋត្រូវដាក់ឧបករណ៍បែបនេះ ឲ្យស្ថិតក្រោមការធ្វើប្រមាណដោយឯករាជ្យនិងតម្លាភាព ដើម្បីកំណត់អំពីការអនុវត្តតាមច្បាប់និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស។ជាពិសេស ឧបករណ៍ គួរត្រូវបានវាយតម្លៃ អំពីភាពសុក្រិតត្រឹមត្រូវ ទំនុកចិត្ត និងសមត្ថភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់ផ្នែករាងកាយនិងចិត្តសាស្ត្រ។ ឧបករណ៍ គួរតែផ្តត់ផ្គង់ឲ្យពេលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបណ្តុះបណ្តាលដោយប្រសិទ្ធភាពដល់មន្ត្រី អំពីការប្រើប្រាស់ត្រឹមត្រូវ។

(ឃ) បទបញ្ញត្តិជាក់លាក់ និងការណែនាំលំអិតពីប្រតិបត្តិ គួរត្រូវបានអភិវឌ្ឍ និងផ្សព្វផ្សាយជាសាធារណៈ ស្តីពីការប្រើប្រាស់ជម្រើសល្បិចកលក្នុងការប្រជុំ រួមមានអាវុធ ដែលទោរទន់ទៅរកការរៀបចំឡើងដោយមិនរើសមុខ ដូចជាឧស្ម័នបង្ហូរទឹកភ្នែកនិងបំពង់បាញ់ទឹក។ ការបណ្តុះបណ្តាល ត្រូវបញ្ចូលការប្រើប្រាស់ឧបករណ៍ដែលមិនសូវគ្រោះថ្នាក់ដល់ជីវិត ដោយស្របតាមច្បាប់និងត្រឹមត្រូវ ក្នុងចំណោមហ្វូងមនុស្ស។ មន្ត្រីអនុវត្តច្បាប់ គួរទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ អំពីឧបករណ៍ការពារ និងទទួលបានការណែនាំយ៉ាងច្បាស់ថា គួរប្រើប្រាស់ឧបករណ៍បែបនេះ ជាជាពិសេសសម្រាប់ការពារ ។ រដ្ឋគួរតាមដានពិនិត្យប្រសិទ្ធភាពនៃការបណ្តុះបណ្តាល នៅក្នុងការបង្កានៃការរំលោភ ការប្រើល្បិចកល ឬ អាវុធខុសគោលដៅ

(ង) អាវុធស្វ័យប្រវត្ត មិនគួរដាក់ឲ្យប្រើប្រាស់នៅក្នុងការឈ្លបយកការណ៍ចំពោះការប្រជុំ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ

(ច) ប្រព័ន្ធអាវុធស្វ័យត ដែលមិនទាមទារមនុស្សបញ្ជា គួរតែហាមប្រាម និងកម្លាំងបញ្ជាពីចម្ងាយ គួរតែប្រើប្រាស់ដោយមានការប្រុងប្រយ័ត្នបំផុត។

(ឆ) រដ្ឋ គួរអភិវឌ្ឍគោការណ៍ណែនាំទូលំទូលាយ អំពីការបំបែកការប្រជុំ អនុលោមទៅតាមច្បាប់និងគោលការណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ គោលការណបែប នេះ គួរតែផ្សាយឲ្យបានដឹងជាសាធារណៈ និងផ្តល់ការណែនាំអនុវត្ត ចំពោះមន្ត្រីអនុវត្ត ច្បាប់ ដោយលំអិត គ្រប់កាលៈទេសៈ ដែលអនុញ្ញាតឲ្យអនុវត្តការបំបែក រាល់វិធានការ ដែលតម្រូវប្រកាន់យក មុនពេលសម្រេចចិត្តធ្វើការបំបែក (រួមមានវិធានការបន្ធូបន្ថយ កំដៅហិង្សា) និងបុគ្គលដែលចេញបញ្ជាបំបែក។

(ជ) រដ្ឋត្រូវបង្កើតប្រព័ន្ធសង្កេតការណ៍និងរាយការណ៍ប្រសិទ្ធភាព ស្តីពីការប្រើ កម្លាំង និងព័ត៌មានដែលពាក់ព័ន្ធ រួមមានតួលេខ អំពីការប្រើកម្លាំងពេលណា មកលើអ្នក ណា ដែលព័ត៌មានទាំងនេះ ងាយស្រួលរកបានជាសាធារណៈ

(ឈ) ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស គួរកោះប្រជុំក្រុមជំនាញការ ដើម្បីពិនិត្យការអនុវត្តប្រព័ន្ធអន្តរជាតិស្តីពីសិទ្ធិមនុស្ស ចំពោះអាវុធដែលបង្កគ្រោះថ្នាក់តិចតួចដល់ជីវិត និងប្រព័ន្ធអាវុធគ្មានមនុស្សបញ្ជា ក្នុងគោលបំណងអនុវត្តច្បាប់ រួមមាន ការផ្តោតលើការប្រើប្រាស់អាវុធនោះ ក្នុងបរិបទ ការប្រជុំ

(ញ) បង្កើតការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីហាមប្រាមការជួញដូរឧបករណ៍ឈ្លបយកការណ៍និងគ្រប់គ្រងហ្វូងមនុស្ស រួមមាន បច្ចេកវិទ្យាឈ្លបយកការណ៍ ដែលឧបករណ៍នោះអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្នុងបរិបទការ ប្រជុំ ដែលអាចសម្រួលដល់ការសម្លាប់ខុសច្បាប់ ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

## ច. មនុស្សគ្រប់រូប ត្រូវមានសិទ្ធិសង្កេតការណ៍ ពិនិត្យតាមដាន និងកត់ត្រាការប្រជុំ

៦៨. បុគ្គលទាំងអស់ មានសិទ្ធិសង្កេតការណ៍ តាមអត្ថន័យពង្រីកបន្ថែម គឺការពិនិត្យតាមដានការប្រជុំ។ សិទ្ធិនេះបានមកពីសិទ្ធិស្វែងរកព័ត៌មាន និងសិទ្ធិទទួល ព័ត៌មាន ដែលត្រូវបានការពារដោយមាត្រា១៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទស្សនៈអំពីការពិនិត្យតាមដាន មិនត្រឹមតែបញ្ជាក់ពី

សកម្មភាពសង្កេតមើលការប្រជុំប៉ុណ្ណោះទេ ប៉ុន្តែជាការប្រមូលព័ត៌មានដ៏សកម្ម ការផ្ទៀងផ្ទាត់និងប្រើព័ត៌មានភ្លាមៗ ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្ស[48]

៦៩. អ្នកសង្កេតការណ៍ ជាទូទៅត្រូវបានកំណត់ថាជាបុគ្គល ឬ ក្រុមភាគីទីបី ដែលមិនមែនជាអ្នកចូលរួម ដែលមានគោលដៅជាចំបង គឺសង្កេតនិងកត់ត្រារាល់អំពើ និងសកម្មភាព ដែលកើតឡើងនៅទីប្រជុំសាធារណៈ[49]។ ស្ថាប័នជាតិសិទ្ធិមនុស្ស មន្ត្រីរាជការ អង្គភាពរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ទាំងអស់គ្នាជាទូទៅ ដើរតួជាអ្នកសង្កេតការណ៍។ អ្នកសារព័ត៌មាន រួមទាំងអ្នកសារព័ត៌មានពលរដ្ឋ មានតួនាទីយ៉ាងសំខាន់[50]

៧០. រដ្ឋមានកាតព្វកិច្ច គោរពសិទ្ធិរបស់អ្នកសង្កេតការណ៍ប្រជុំ។ កាតព្វកិច្ចនោះ រួមមានការគោរពនិង សម្រួលសិទ្ធិសង្កេតការណ៍និងតាមដាន នូវរាល់ទិដ្ឋភាពទាំងអស់នៃការប្រជុំ ដោយរងការដាក់កម្រិតតូចដ៏ចង្អៀត ដែលបានអនុញ្ញាតក្នុងមាត្រា ១៩(៣)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ អ្នកសង្កេតការណ៍ រក្សាទុកសិទ្ធិមនុស្សដទៃទៀតទាំងអស់។ រដ្ឋ គួរស៊ើបអង្កេតពេញលេញរាល់ការរំលោភបំពានសិទ្ធិមនុស្ស មកលើអ្នកសង្កេតការណ៍ ហើយគួរ អនុវត្តការកាត់ទោសនិងផ្តល់ដំណោះស្រាយ គ្រប់គ្រាន់។ ការការពារដែលផ្តល់ដល់អ្នកសង្កេតការណ៍ គឺអនុវត្តដោយមិនចាំបាច់ ពិចារណាថាការប្រជុំនោះកើតឡើងដោយសន្តិវិធីឬអត់។

៧១. គ្រប់ៗរូប ទោះជាអ្នកចូលរួម អ្នកសង្កេតការណ៍ ឬអ្នកសង្កេត ត្រូវមានសិទ្ធិកត់ត្រាការប្រជុំ រួមទាំងសិទ្ធិកត់ត្រាប្រតិបត្តិការណ៍អនុវត្តច្បាប់។ សិទ្ធិនេះរួមទាំងសិទ្ធិកត់ត្រាអំពើអន្តរកម្ម ដែលពួកគេត្រូវបានថតទុកដោយភ្នាក់ងាររដ្ឋ នៅពេលខ្លះនិយាយដល់សិទ្ធិ"ថតត្រឡប់វិញ"។ រដ្ឋ គួរការពារសិទ្ធិនេះ។ ការដកហូត រឹបអូស និង/ឬការបំផ្លាញកំណត់ហេតុនិងឧបករណ៍ថតសោតទស្សន៍និងសម្លេង ត្រូវហាមឃាត់ និងត្រូវទទួលទោស បើគ្មានគោលការណ៍តាមច្បាប់

48 ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, *កូនសៀវភៅណែនាំការបណ្តុះបណ្តាល ស្តីពីសង្កេតការណ៍សិទ្ធិមនុស្ស* (ផ្សព្វផ្សាយដោយ អង្គការសហប្រជាជាតិ, លក់ No. E.01.XIV.2), កឋាខណ្ឌ ២៨

49 OSCE/ODIHR, *គោលការណ៍ណែនាំ*, កឋាខណ្ឌ. ២០១

50 សូមមើល, ឧទាហរណ៍, OSCE, “របាយការណ៍ពិសេស : ដំណោះស្រាយជាមួយប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន អំឡុងពេលបាតុកម្មនយោបាយ” (២០០៧)។

៧២. **អនុសាសន៍អនុវត្តៈ**

(ក) រដ្ឋ គួរធានាការដាក់ឲ្យដំណើរការនូវយុទ្ធសាស្ត្រចូលរួមរបស់សហគមន៍ ដោយឲ្យបានទូលំទូលាយ ដែលរួមមានកម្មវិធី និងគោលនយោបាយ ដែលបាន តាក់តែងបង្កើតទំនុកចិត្តនិងទំនាក់ទំនងជាមួយមន្ត្រីអនុវត្តច្បាប់ សារព័ត៌មាន និង ជាមួយ អ្នកសង្កេតការណ៍ការប្រជុំដទៃទៀត

(ខ) អាជ្ញាធរ គួរប្រាស្រ័យទាក់ទងជាមួយអ្នកសង្កេតការណ៍ សម្រាប់ផ្លាស់ប្តូរ ដោយទំនាក់ទំនងតាមរបៀបដូចគ្នា មុនពេល អំឡុងពេល និងក្រោយពេលការប្រជុំ ផ្តល់ច្រកចេញចូល និងព័ត៌មានទៅកាន់សមាជិកសារព័ត៌មាន និងអ្នកសង្កេតការណ៍ ដទៃទៀត និងពិចារណា និងឆ្លើយតបទៅរបាយការណ៍របស់អ្នកសង្កេតការណ៍ ក្រោយពេលប្រជុំ។

(គ) អាជ្ញាធរ គួរជូនដំណឹងជាប្រចាំ ដល់ស្ថាប័ននានា ឬ ស្ថាប័ន ពិនិត្យសង្កេតដែលឯករាជ្យ និងពាក់ព័ន្ធដទៃទៀត ដែលប្រមើលមើលលើការប្រជុំ និងសម្រួលការចេញចូលដែលទាមទារឲ្យពួកគេពិនិត្យមើលដោយត្រឹមត្រូវទៅលើការប្រ ជុំនៅគ្រប់ដំណាក់កាលទាំងអស់

(ឃ) តាមច្បាប់ រដ្ឋគួរហាមប្រាមការជ្រៀតជ្រែកណាមួយ ក្នុងការថតអំពី ការប្រជុំ រួមមានការរឹបអូស ឬការបង្កការខូចខាតដល់ឧបករណ៍អ្វីមួយ លើកលែងតែ មានដីកាយោងពីចៅក្រមដែលគាត់ពិចារណាថាវាមានភស្តុតាងគ្រប់គ្រាន់សម្រាប់ការ កាត់ក្តី។

## ឆ. ការប្រមូលព័ត៌មានរបស់បុគ្គល ដែលទាក់ទងនឹងការប្រជុំ មិនអនុញ្ញាត-ឲ្យជ្រៀតជ្រែក ក្នុងជីវិតឯកជន ឬសិទ្ធិដទៃទៀតឡើយ

៧៣. ការប្រមូលព័ត៌មានសុក្រិត ដោយមន្ត្រីអនុវត្តច្បាប់ អាចជាផលប្រយោជន៍ ដល់ការគ្រប់គ្រងដ៏ត្រឹមត្រូវនៃការប្រជុំ ទុកឲ្យមន្ត្រីអនុវត្តច្បាប់ អាចបំពេញការទទួល ខុសត្រូវ ដើម្បីរៀបចំ និងសម្រួលការប្រជុំដោយសន្តិវិធី។ ការប្រមូល និងដំណើរប្រព្រឹត្ត នៃព័ត៌មាន ដូចជាឧបករណ៍ថត កាមេរ៉ាសុវត្ថិភាព ការឈ្លបយកការណ៍ដោយសម្ងាត់ ត្រូវអនុវត្តដើម្បីការការពារប្រឆាំងនឹងការជ្រៀតជ្រែក ខុសច្បាប់ ឬតាមអំពើចិត្ត ជាមួយ នឹងជីវិតឯកជន

៧៤. នីត្យានុកូលភាពនិងគោលនយោបាយ ដែលកម្រិតលើការប្រមូល និងដំណើរ ប្រព្រឹត្តនៃព័ត៌មាន ដែលទាក់ទងនឹងការប្រជុំ ឬអ្នករៀបចំនិងអ្នកចូលរួម គឺត្រូវតែច្របាច់ បញ្ចូល នីស្សានុភាព ការចាំបាច់ និងគេស្តុសមាមាត្រ។ ដោយដឹងអំពីការរំលោភ

លើវិធីសាស្រ្តបែបនេះហើយ ការធ្វើតេស្តទាំងនេះ គឺមានកំរិតខ្ពស់ជាពិសេស។ ប្រសិនបញ្ញត្តិច្បាប់និងគោលការណ៍ទាំងនោះ ជ្រៀតជ្រែកក្នុងការប្រើប្រាស់សិទ្ធិនោះ ការប្រមូលទិន្នន័យ និងដំណើរប្រព្រឹត្តទិន្នន័យ អាចបង្ហាញឲ្យឃើញអំពីការរំលោភសិទ្ធិសិរីភាពនៃការប្រជុំដោយសន្តិវិធី និងការសម្តែងមតិ

៧៥. សមត្ថភាពនៃការប្រើបច្ចេកវិទ្យាទំនាក់ទំនង ដោយសុវត្ថិភាពនិងតាមលក្ខណៈឯកជន គឺសំខាន់ជាអាយុជីវិត ចំពោះការរៀបចំ និងរបៀបនៃប្រជុំ។ ការដាក់កំហិតទៅលើសេវាអ៊ិនធឺណេត ឬ ការសម្តែងមតិ ត្រូវតែ តម្រូវការចាំបាច់ និងសមាមាត្រ ហើយអនុវត្តដោយស្ថាប័នឯករាជ្យពីឥទ្ធិពលនយោបាយ ពាណិជ្ជកម្ម ឬឥទ្ធិពលផ្សេងៗទៀតដែលគេមិនចង់បាន ហើយគួរមានការការពារគ្រប់គ្រាន់ ប្រឆាំងនឹងការរំលោភ (សូមមើលA/HRC/17/27 កឋាខណ្ឌ៦៩)។ ការរាំងខ្ទប់ទំនាក់ទំនង – ដែលបង្អាក់ការរៀបចំ ឬការផ្សព្វផ្សាយការប្រជុំមួយនៅលើប្រព័ន្ធអ៊ិនធឺណេត – មិនបំពេញតម្រូវការទាំងនេះទេ (ibid., កឋាខណ្ឌ៣១)។

៧៦. ខណៈដែលមានការលើកហេតុផលអំពីការអនុវត្តច្បាប់តាមនីតិវិធី និងគណនីយ្យភាព ដើម្បីកត់ត្រាការប្រជុំមួយនោះ សកម្មភាពថតអ្នកចូលរួមអាចជះឥទ្ធិពលធ្ងន់ធ្ងរ មកលើការប្រើប្រាស់សិទ្ធិ រួមមានសេរីភាពនៃការប្រជុំសិទ្ធិសមាគម និងការសម្តែងមតិ។ ការថតអ្នកចូលរួមការប្រជុំដោយសន្តិវិធីនៅក្នុងបរិបទមួយនិងរបៀបមួយដែលគំរាមកំហែង ឬដោយឃាឃី គឺជាការជ្រៀតជ្រែកដែលគ្មានការអនុញ្ញាត លើសិទ្ធិទាំងនេះ

៧៧. ការប្រើប្រាស់មន្រ្តីបង្កប់ ដើម្បីប្រមូលព័ត៌មានចារកម្ម ដែលទាក់ទងទៅនឹងការប្រជុំ គឺជាបញ្ហា។ វាជាការរំលោភធ្ងន់ធ្ងរ និងមានហានិភ័យខ្ពស់ ចំពោះការរំលោភសិទ្ធិដូច្នេះមិនគួរអនុញ្ញាតឡើយ ទាល់តែមានសំអាងហេតុផល សង្ស័យថាការប្រព្រឹត្តអំពើឧក្រិដ្ឋធ្ងន់ធ្ងរ ទំនងអាចកើតឡើង។ អាជ្ញាធរ គួរពិចារណាអំពីការស្នើសកម្មភាពបង្កប់ ដែលជាវិធីសាស្រ្តតែមួយប៉ុណ្ណោះ ក្នុងការទទួលបានព័ត៌មាន ហើយតម្លៃព័ត៌មានត្រូវធ្វើយុត្តិកម្មជាមួយនឹងការរំលោភ។ គួរគិតគូរអំពីផលប៉ះពាល់ មកលើសិទ្ធិរបស់ជនទាំងឡាយដែលរងប៉ះពាល់ទាំងអស់ មិនត្រឹមតែជនគោលដៅប៉ុណ្ណោះទេ

៧៨. **អនុសាសន៍អនុវត្តៈ**

(ក) ច្បាប់ក្នុងស្រុក គួរតម្រូវឲ្យជូនដំណឹងដល់សាធារណៈជន នៅពេលពួកគេត្រូវបានថត ឬអាចថត អំឡុងពេលប្រជុំ។ ឧទាហរណ៍ តម្រូវឲ្យដាក់សញ្ញាសម្គាល់បណ្តោះអាសន្ន នៅតាមផ្លូវដែលការប្រជុំឆ្លងកាត់ ដោយបញ្ជាក់ថាមានដាក់កាមេរ៉ា ឬការណែនាំថាមានឧបករណ៍ដែលគ្មានមនុស្សបញ្ជា កំពុងថតពីលើអាកាស

(ខ) រដ្ឋ គួរអនុវត្តនូវកិច្ចការពារជិវិតឯកជន និងសុវត្ថិភាព ឲ្យបានត្រឹមត្រូវ និងម៉ត់ចត់ មុនពេលការអនុម័តនូវបច្ចេកវិទ្យាព័ត៌មានជីវសាស្ត្រ រួមមានកម្មវិធីកុំព្យូទ័រ ដែលអាចកំណត់អត្តសញ្ញាណមុខ ក្នុងបរិបទការប្រជុំ

(គ) រដ្ឋ គួរអភិវឌ្ឍ និងអនុវត្តច្បាប់ គោលនយោបាយ ដែលតម្រូវអោយមានការប្រមូលនិងរក្សាព័ត៌មានផ្ទាល់ខ្លួន សម្រាប់គោលបំណងពង្រឹងផ្លូវច្បាប់ ដោយស្រប ច្បាប់តាមនីតិវិធី។ ព័ត៌មានបែបនោះ ត្រូវបំផ្លាញចោល ក្រោយពេលកំណត់សមស្រប ដែលបានចែងក្នុងច្បាប់

(ឃ) ទោះជាយ៉ាងណាក៏ដោយ ត្រូវរក្សាទុកព័ត៌មានណាដែលបង្ហាញ អំពីការប្រើប្រាស់កម្លាំង ការឃុំខ្លួន ឬចាប់ខ្លួន ឬការបំបែក ឬ ទាក់ទងទៅនឹងកម្មវត្ថុ ដែលពាក្យបណ្តឹង ឬការពង្រឹងច្បាប់ ការពិនិត្យមើលរបស់អាជ្ញាធរ ឬប្រធានបទព័ត៌មាន ដែលមានការសង្ស័យសមហេតុផល ថាបទឧក្រិដ្ឋ ឬកំហុសសីលធម៌ ត្រូវបានប្រព្រឹត្តិឡើង

(ង) រដ្ឋ គួរបង្កើតយន្តការមួយ ដែលតាមរយៈយន្តការនោះធ្វើឲ្យបុគ្គលប្រាកដក្នុងចិត្តថាតើមាន ឬ គ្មានការរក្សាទុកព័ត៌មាន ប្រសិនមាន តើព័ត៌មានរក្សាទុក តើព័ត៌មាននោះជាអ្វី ហើយពួកគេមានសិទ្ធិទទួលបានព័ត៌មាន ដោយឆ្លងកាត់ដំណើរការធ្វើពាក្យបណ្តឹង ទាក់ទងនឹងការប្រមូល ការរក្សាទុក និងការប្រប្រាស់ព័ត៌មានផ្ទាល់ខ្លួន ដែលឈានដល់ការកែតម្រូវ ឬការលុបបំផ្លាញព័ត៌មានចោល

(ច) រដ្ឋ គួរបង្កើតឡើងប្រព័ន្ធប្រជាធិបតេយ្យច្បាស់លាស់ អំពីការគ្រប់គ្រងតាមឈ្លបយកការណ៍ដែលបង្កប់ តាមរយៈបទបញ្ញត្តិ បទបញ្ជា និងគោលនយោបាយដូចៗគ្នា ដែលបញ្ចូលគ្នានូវតម្រូវការចាំបាច់ និង ធ្វើតេស្តសមាមាត្រ ឲ្យបានច្បាស់លាស់ ហើយត្រូវដាក់ចេញនូវវិធីសាស្ត្រ ក្នុងការធ្វើប្រមាណនិងគ្រប់គ្រងទៅលើហានិភ័យនៃការរំលោភបំពាន។ គួររាប់បញ្ចូលដំណើរការត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងការពិនិត្យមើលដោយស្ថាប័នខាងក្រៅមួយឬច្រើន ដែលឯករាជ្យ។ គួរតម្រូវការអនុញ្ញាតពីអាជ្ញាធរតុលាការ ដើម្បីធ្វើសកម្មភាពឈ្លបយកការណ៍ដែលបង្កប់ នៅក្នុងបរិបទនៃការប្រជុំ។

## ជ. បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងការប្រជុំ

៧៩.ការផ្តល់លទ្ធភាពបុគ្គល អាចទទួលបានព័ត៌មាន គឺរឿងសំខាន់ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគាត់ នៅក្នុងបរិបទការប្រជុំ និងធានានូវគណនីយ្យភាព។ព័ត៌មានរួមមាន

កំណត់ត្រាទុកដោយស្ថាប័នសាធារណៈគ្រប់ជាន់ថ្នាក់ ឬស្ថាប័នឯកជនដែលបំពេញតួនាទីសាធារណៈ[51]

៨០. សាធារណជន គួរមានសិទ្ធិទទួលព័ត៌មានភ្លាមៗ ងាយស្រួល និងប្រសិទ្ធភាព តាមរយៈការបញ្ចេញឲ្យដឹងជាមុន និងការអនុវត្តបទបញ្ញត្តិ ដើម្បីសម្រួលដល់ការទទួលបានជាសាធារណៈចំពោះព័ត៌មាន។ បញ្ញត្តិដែលសម្រួលដល់ការទទួលបានព័ត៌មានបែបនេះ គួរផ្អែកលើគោលការណ៍ បញ្ចេញព័ត៌មានជាអតិបរមា ដោយសន្មត់ថាព័ត៌មានអាចទទួលបាន ដោយលើកលែងតែករណីពិសេសប៉ុណ្ណោះ[52]

៨១. ករណីពិសេសចំពោះសិទ្ធិទទួលបានព័ត៌មាន គួរតែកំណត់ដោយប្រយ័ត្ន ដើម្បីការពារសាធារណជនដែលសំខាន់ជាងអ្វីៗទាំងអស់ និងប្រយោជន៍ឯកជន រួមទាំងជីវិតឯកជន។ ករណីពិសេស គួរតែអនុវត្ត ពេលដែលអាចមានគ្រោះថ្នាក់ខ្លាំងទៅដល់ផលប្រយោជន៍ដែលបានការពារ និងពេលដែលគ្រោះថ្នាក់ មានទំហំធំជាងប្រយោជន៍សាធារណៈទាំងមូល ក្នុងការទទួលបានព័ត៌មាន[53] ។ អាជ្ញាធរសាធារណៈត្រូវទទួលខុសត្រូវ ដើម្បីបង្ហាញថា ព័ត៌មានស្ថិតនៅក្នុងវង្វង់នៃករណីពិសេស[54] ។ សេចក្តីសម្រេចចិត្តរបស់អាជ្ញាធរ ត្រូវមានការពិនិត្យមើលឡើងវិញ ការសម្រេចចិត្តរបស់អាជ្ញាធរ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ

៨២. **អនុសាសន៍អនុវត្តះ**

(a) រដ្ឋគួរធ្វើសកម្មភាពផ្សព្វផ្សាយជាមុន អំពីព័ត៌មានសំខាន់ៗ ដែលទាក់ទងនឹងការគ្រប់គ្រងការប្រជុំ។ ព័ត៌មានបែបនោះគួររួមមានៈ- ច្បាប់ បទបញ្ញត្តិ ព័ត៌មានដែលទាក់ទងនឹងការទទួលខុសត្រូវនិងនីតិវិធីរបស់ភ្នាក់ងារនិងស្ថាប័ន ដែលគ្រប់គ្រងការប្រជុំ បទដ្ឋានដែលប្រតិបត្តិការនីតិវិធីនិងគោលនយោបាយ រួមមានក្រមសីលធម៌ ការគ្រប់គ្រងការឈ្លបយកការណ៍របស់ប៉ូលិស ទៅលើការប្រជុំ ប្រភេទឧបករណ៍ ដែលប្រើជាប្រចាំក្នុងការឈ្លបយកការណ៍លើការប្រជុំ ព័ត៌មានស្តីពីការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ និងព័ត៌មានស្តីពីវិធីក្នុង ដំណើរការគណនីយ្យភាព

---

[51] សូមមើល គណកម្មាធិការសិទ្ធិមនុស្ស, ការពន្យល់ទូទៅលេខ ៣៤(២០១១) ស្តីពីសេរីភាពនៃការសម្តែងមតិ, កឋាខណ្ឌ ១៨។ សូមមើលសេចក្តីប្រកាស នូវគោលការណ៍ស្តីពីសេរីភាពនៃការសម្តែងមតិ នៅអាហ្វ្រិក

[52] សេចក្តីប្រកាសរួម ដោយអ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិ ស្តីពី ការលើកស្ទួយ និងការពារ សិទ្ធិសេរីភាពនៃការសម្តែងមតិ, តំណាង OSCE ទទួលបន្ទុកផ្នែកសេរីភាពសារព័ត៌មាន និងអ្នករាយការណ៍ពិសេស OAS សម្រាប់សេរីភាពក្នុងការសម្តែងមតិ ស្តីពីសិទ្ធិទទួលបានព័ត៌មាន (៦ ធ្នូ ២០០៤)។

[53] Ibid.

[54] Ibid.

(ខ) រដ្ឋ គួរអនុម័តបញ្ញត្តិឲ្យទូលំទូលាយ ឧទាហរណ៍សេចក្តីសម្រេច អំពីសេរីភាពព័ត៌មាន ដើម្បីសម្របសម្រួលការទទួលបានព័ត៌មានជាសាធារណៈ ដោយផ្អែកលើគោលការណ៍នៃការបញ្ចេញព័ត៌មានជាអតិប្បរិមា។ រដ្ឋ គួរគ្រប់គ្រង ព័ត៌មាន ដែលមានលក្ខណៈទូលំទូលាយ ងាយស្រួលទទួលបាន ហើយគួរឆ្លើយតប ជាបន្ទាន់ និងពេញលេញ ចំពោះការស្នើសុំព័ត៌មានទាំងអស់ និងគួរឆ្លើយតបភ្លាមៗ និងពេញលេញ ចំពោះរាល់សំណើរសុំព័ត៌មាន ទាំងអស់។

(c) រដ្ឋ គួរបង្កើតយន្តការត្រួតពិនិត្យដោយប្រសិទ្ធភាព ដែលរដ្ឋមាន អំណាចខ្លះៗ ដើម្បីទទួលនិងស៊ើបអង្កេត ពាក្យបណ្តឹង និងដើម្បីបង្កើត បទបញ្ញាដែលចាប់បង្ខំ សម្រាប់ការបញ្ចេញព័ត៌មានណា ដែលផ្តល់ប្រយោជន៍ដល់ អ្នកដាក់ពាក្យ ឬ អ្នកធ្វើបណ្តឹង

## ឈ. សហគ្រាសធុរកិច្ច មានការទទួលខុសត្រូវ គោរពសិទ្ធិមនុស្ស ក្នុងបរិបទការប្រជុំ

៨៣. សហគ្រាសធុរកិច្ច មានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស រួមទាំងក្នុងបរិបទការប្រជុំ។ ក្រុមហ៊ុនអាជីវកម្ម ត្រូវជៀសវាង ឬបង្កនូវផលប៉ះពាល់អាក្រក់មកលើសិទ្ធិមនុស្ស និងត្រូវដោះស្រាយអំពីផលប៉ះពាល់អាក្រក់មកលើសិទ្ធិមនុស្ស ដែលខ្លួនពាក់ព័ន្ធ[55] ។ ផលប៉ះពាល់នេះភ្ជាប់នឹងប្រតិបត្តិការជំនួញ ផលិតផល និងសេវារបស់ក្រុមហ៊ុនអាជីវកម្មមួយដែលធ្វើការផ្គត់ផ្គង់ឧបករណ៍ ឬ អាវុធដែលមិនសូវគ្រោះថ្នាក់ដល់ជីវិត ឬ បច្ចេកវិទ្យាឈ្លបយកការណ៍ ដែលប្រើសម្រាប់ឈ្លបយកការណ៍ នៅពេលប្រជុំ

៨៤. និន្នាការឆ្ពោះទៅរកឯកជនភាវូនីយកម្ម នៃទីធ្លាសាធារណៈ ដូចជាហាងលក់ទំនិញធំៗ សង្កាត់សម្រាប់អ្នកថ្មើជើង និងទីលានផ្សេង គឺមានន័យថាការ ប្រជុំកើតឡើងជាធម្មតានៅលើទីធ្លាកម្មសិទ្ធដែលគ្រប់គ្រងដោយសហគ្រាសអាជីវកម្ម ពេលខ្លះសំដៅទៅលើទីធ្លាសាធារណៈដែលគ្រប់គ្រងដោយឯកជន។ ខណៈដែលម្ចាស់កម្មសិទ្ធ ឯកជន ជាទូទៅមានសិទ្ធិកំណត់ ថាអ្នកណាអាចចេញចូលក្នុងទីតាំងបាន សិទ្ធិទាក់ទងនឹងការប្រជុំ គឺអាចទាមឲ្យមានវិធានការជាវិជ្ជមាន ក្នុងការការពារនៅក្នុងដែនទំនាក់ទំនងរវាងបុគ្គល[56]

---

[55] គោលការណ៍ណែនាំ ១១ និង ១៣ (ក) នៃគោលការណ៍ណែនាំ ស្តីពីទុរកិច្ច និងសិទ្ធិមនុស្ស: អនុវត្ត ប្រព័ន្ធ "ការពារ គោរព និងវិធីដោះស្រាយ" អង្គការសហប្រជាជាតិ (A/HRC/17/31), annex.

[56] លក្ខន្តិក: *PlattformÄrtzefür das Leben v. Austria*, កឋាខណ្ឌ. ៣២

៨៥. សហគ្រាសអាជីវកម្ម មានតួនាទីសំខាន់កាន់តែខ្លាំងឡើង ក្នុងការឈ្លបយកការណ៍ពីការប្រជុំផងដែរ។ ឧទាហរណ៍ ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន អាចបំពេញតួនាទីឈ្លបយកការណ៍ ខណៈដែលកំពុងការពារទ្រព្យសម្បត្តិឯកជន អំឡុងពេលប្រជុំ។ ក្រុមហ៊ុនឯកជន ជាញឹកញាប់ បំពេញមុខងារឈ្លបមើល (សូមមើល A/HRC/23/39/Add.1 កឋាខណ្ឌ៣៣)។ ស្ថាប័នអាជីវកម្ម គួរអនុវត្តភាពហ្មត់ចត់អំពីសិទ្ធិមនុស្ស[57] និងផលប៉ះពាល់ខ្លាំងទៅលើការប្រជុំនិងសិទ្ធិនិងសិទ្ធិដទៃទៀត ដើម្បីបន្ធូរបន្ថយហានិភ័យទាំងនេះ។ ក្រុមហ៊ុនសេវាសន្តិសុខឯកជន មិនគួរបំពេញមុខងារ ឈ្លបយកការណ៍ ដែលទាក់ទងនឹងការប្រជុំឡើយ។ ទោះជាយ៉ាងណា ក្រុមហ៊ុនផ្តល់សេវាទាំងនោះត្រូវគោរពនិងការពារសិទ្ធិមនុស្ស[58]និងគួរអនុវត្តតាមបទដ្ឋានខ្ពស់បំផុតនៃការប្រព្រឹត្ត ដោយស្ម័គ្រចិត្ត[59]

៨៦. ជាទូទៅស្ថាប័នធុរកិច្ច ស្វែងរកអធិបញ្ញាតុលាការ និងវិធីដំណោះស្រាយរដ្ឋប្បវេណីផ្សេងៗ ប្រឆាំងនឹងការរៀបចំ និងអ្នកចូលរួមការប្រជុំ ដោយឈរលើមូលដ្ឋានឧទាហរណ៍ ដូចជាច្បាប់ប្រឆាំងការឃាយឺ ច្បាប់ហាមឆ្លងកាត់ ឬច្បាប់បង្ខូចកេរ្តិ៍ឈ្មោះ ដែលពេលខ្លះ យោងទៅលើបណ្តឹងតុលាការដែលជាយុទ្ធសាស្ត្រ ដើម្បីប្រឆាំងនឹងការចូលរួមសាធារណជន។ រដ្ឋមានកាតព្វកិច្ចដើម្បីធានា ដំណើរប្រព្រឹត្តិត្រឹមត្រូវតាមនីតិវិធី និងការពារពលរដ្ឋ ពីបន្តឹងរដ្ឋប្បវេណី ដែលខ្វះអង្គសេចក្តី។

៨៧. រដ្ឋ អាចទទួលខុសត្រូវ ចំពោះការរំលោភសិទ្ធិមនុស្ស ដោយតួអង្គដែលមិនមែនរដ្ឋ ប្រសិនបើរដ្ឋ យល់ព្រម គាំទ្រ ឬសុខចិត្តទទួលស្គាល់ច្បាប់ទាំងអស់នោះ ដោយខកខានអនុវត្តការប្រុងប្រយ័ត្នហ្មត់ចត់ក្នុងការបង្ការការរំលោភ ឬខកខានធានាការស៊ើប អង្កេតត្រឹមត្រូវ និងគណនីយ្យភាព។ រដ្ឋមានភារកិច្ចមានភារកិច្ច ចាត់វិធានការ សមស្របផងដែរ ដើម្បីបង្ការ ស៊ើបអង្កេត និង ផ្តល់វិធីដោះស្រាយប្រសិទ្ធភាព ចំពោះការប្រព្រឹត្តអសីលធម៌ ដោយសហគ្រាសអាជីវកម្ម ហើយចាប់បង្ខំឲ្យភាគីឯកជន ឲ្យខុសត្រូវឲ្យទទួលខុសត្រូវចំពោះការបង្កឲ្យ និងនាំឲ្យមានការដកហូត ជីវិតតាមអំពើចិត្ត នៅក្នុងដែនទទួលខុសត្រូវ ឬទឹកដីរបស់រដ្ឋ។ .

---

[57] សូមមើលគោលការណ៍ ១៧-២១ នៃគោលការណ៍ណែនាំ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស

[58] សូមមើលគោលការណ៍ណែនាំ ស្តីពីទុរកិច្ច និងសិទ្ធិមនុស្ស, និង ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន នឹងឧក្រិដ្ឋកម្ម, *និយ័តកម្មរបស់រដ្ឋដែលទាក់ទងនឹង សេវាសន្តិសុខឯកជនរបស់ពលរដ្ឋ និងការរយមចំណែករបស់ពួកគេដើម្បីបង្ការឧក្រិដ្ឋកម្ម និងសុវត្ថិភាពសហគមន៍* (២០១៤)

[59] សូមមើល, ឧទាហរណ៍, គោលការណ៍ស្ម័គ្រចិត្តស្តីពីសន្តិសុខ និងសិទ្ធិមនុស្ស (២០០០), អាចរកមាននៅ www.voluntaryprinciples.org/.

៨៨. **អនុសាសន៍អនុវត្តៈ**

(ក) រដ្ឋ គួរការពារបុគ្គលគ្រប់រូប ពីការជ្រៀតជ្រែកលើសិទ្ធិរបស់ពួកគេ ដោយសហគ្រាសអាជីវកម្ម ក្នុងបរិបទការប្រជុំ ដោយប្រកាន់យកវិធានការអនុវត្ត ដោយទទួលខុសត្រូវ ដែលបានបំភ្លឺនៅក្នុងគោលការណ៍ណែនាំ អំពីធុរកិច្ចនិងសិទ្ធិមនុស្ស។

(ខ) ប្រសិនទីធ្លាជាកម្មសិទ្ធឯកជន បើកចំហ ចំពោះសាធារជនទូទៅ និងមានមុខងារបម្រើជាទីធ្លាសាធារណៈ ដូច្នេះទីធ្លាទាំងនោះ គួរចាត់ទុកថាជាកន្លែងសាធារណៈ សម្រាប់គោលបំណងការសម្ដែងមតិ និងសិទ្ធិ សេរីភាពនៃការប្រជុំ

(គ) រដ្ឋ គួរណែនាំដល់អ្នករៀបចំការប្រជុំ និងអ្នកចូលរួម ឲ្យដឹងអំពីការពារពារពីបណ្ដឹងរដ្ឋប្បវេណី ដែលរៀបចំឡើងជារឿងលេងសើចឥតបានការ ឬដែលមានបំណងបន្លាចសាធារណជនមិនអោយចូលរួម

## ញ. រដ្ឋនិងស្ថាប័នរបស់ខ្លួន ត្រូវច្បាប់បង្ខំឲ្យទទួលខុសត្រូវចំពោះ ទង្វើរបស់ខ្លួន ដែលពាក់ព័ន្ធនឹងការប្រជុំ

៨៩. រដ្ឋ មានកាតព្វកិច្ច ផ្ដល់វិធីដំណោះស្រាយ ដោយប្រសិទ្ធភាព ជាបន្ទាន់ និងគ្រប់គ្រាន់ ចំពោះបុគ្គលណាដែលសិទ្ធិរបស់ពួកគាត់ត្រូវបានរំលោភក្នុង បរិបទការប្រជុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ដែលមានអំណាចអនុវត្តវដំណោះស្រាយ[60] ។ សិទ្ធិទទួលបានដំណោះស្រាយ រួមមានសិទ្ធិស្មើគ្នានិងប្រសិទ្ធភាព ក្នុងការទទួលបានយុត្តិធម៌ សំណងរងការខូចខាត ជាបន្ទាន់និងប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលព័ត៌មាន ដែលទាក់ទងនឹងអំពើរំលោភ និងយន្តការសំណង

៩០. រដ្ឋ ត្រូវស៊ើបអង្កេតជាបន្ទាន់ និងដោយប្រសិទ្ធភាព រាល់បទចោតប្រកាន់ដែលគ្មានភស្តុតាង អំពីបទរំលោភ នៅក្នុងបរិបទប្រជុំ តាមរយៈស្ថាប័នឯករាជ្យ និងមិនលំអៀង។ បន្ថែមពីនេះទៀត សមាសភាពទម្រង់ការ នៃសិទ្ធិរស់រានមានជីវិត ទាមទារឲ្យរដ្ឋ ស៊ើបអង្កេតរាល់បទចោតប្រកាន់ដែលគ្មានភស្តុតាង នៃការសម្លាប់តាមអំពើចិត្ត ឬខុសច្បាប់។ ការខកខានរបស់រដ្ឋ ក្នុងការស៊ើបអង្កេតដែលត្រឹមត្រូវ អំពីការសម្លាប់តាមអំពើចិត្ត ឬខុសច្បាប់ គឺជាការរំលោភលើសិទ្ធិរស់រានមានជីវិត(A/70/304).។ ដូចគ្នានេះដែរ កង្វះខាត នៃការទទួលខុសត្រូវ ចំពោះការរំលោភសិទ្ធិ

[60] សូមមើលគណកម្មាធិការសិទ្ធិមនុស្ស, ការបន្យល់ជាទូទៅ លេខ ៣១, កឋាខណ្ឌ ១៥។ សូមមើលផលដែរ គោលការណ៍មូលដ្ឋានគ្រឹះ និងគោលការណ៍ណែនាំ ស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ នឹងសំណង សម្រាប់ជនរងគ្រោះ នៃការរំលោភធ្ងន់ធ្ងរ នៃច្បាប់អន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងការរំលោភធ្ងន់ធ្ងរនៃច្បាប់អន្តរជាតិស្ដីពីមនុស្សធម៌។

ចំពោះបុរណភាពរាងកាយ អាចជាអំពើរំលោភលើសិទ្ធិទាំងនោះ[61] ដោយខ្លួនឯង។ ការស៊ើបអង្កេតដែលប្រសិទ្ធភាព រួមមានកត្តាដូចតទៅនេះ ៖ ការស៊ើបអង្កេតជា ផ្លូវការ មួយ ដែលផ្តួចផ្តើមដោយរដ្ឋ ឯករាជ្យពីអ្នកដែលពាក់ព័ន្ធ សមត្ថភាពក្នុងការកំណត់អំពើមួយ ថាតើត្រូវបានធ្វើយុត្តិកម្ម ក្នុងកាលៈទេសៈទាំងនោះ ឬអត់ កំរិតនៃភាពរួសរាន់ និងភាពរួសរាន់សមហេតុសមផល និងកំរិតនៃការពិនិត្យពិច័យសាធារណៈ[62]

៩១. ប្រសិនណ្ឌកម្មបទឧក្រិដ្ឋ និង/ឬទណ្ឌរដ្ឋប្បវេណីដែលសមស្រប ត្រូវអនុវត្ត។ ការទទួលខុសត្រូវ គួរភ្ជាប់ទៅនឹងមន្ត្រី ដែលមានភារកិច្ចគ្រប់គ្រងបទបញ្ជា ដែលពួកគាត់បានទទួលបរាជ័យក្នុងអនុវត្តបទបញ្ជានិងគ្រប់គ្រងឲ្យបានប្រសិទ្ធភាព។ ប្រើសិនមន្ត្រីថ្នាក់លើបានដឹង ឬគួរតែដឹងថា មន្ត្រីអនុវត្តច្បាប់ ដែលស្ថិតក្រោមឱវាទបញ្ជារបស់ខ្លួន ដែលបានប្រើប្រាស់កម្លាំង ឬអាវុធខុសច្បាប់ និងពួកគាត់មិនបានចាត់វិធានការអ្វីទាំងអស់ នៅក្នុងអំណាចរបស់ខ្លួន ដើម្បីបង្ការ បង្ក្រាប ឬរាយការណ៍អំពីការប្រើប្រាស់បែបនេះ នោះគួរតែចាប់បង្ខំពួកគាត់ឲ្យទទួលខុសត្រូវ[63]

៩២. ការប្រើប្រាស់ត្រឹមត្រូវនៃម៉ាស៊ីនថតដែលភ្ជាប់នឹងខ្លួន ដោយមន្ត្រីអនុវត្តច្បាប់ នៅក្នុងបរិបទប្រជុំគ្នា អាចជួយសម្រួលដល់ការងារស៊ើបអង្កេតផ្ទៃក្នុង ឬយន្តការត្រួតពិនិត្យជនស៊ីវិល។ បច្ចេកវិទ្យាបែបនេះ ទើបតែចាប់ផ្តើម ហើយការថ្លឹងថ្លែងដែលងាយៗ អំពីការរំលោភដែលអាចប្រព្រឹត្តិឡើង គួរតែយកមកពិចារណា។ ប៉ុន្តែនៅតំណាក់កាលនេះ គួរមានលទ្ធភាព ដើម្បីលើកស្ទួយ គណនីយ្យភាព ដែលបង្កើតឡើងនូវការការពារគ្រប់គ្រាន់

៩៣. ព្រះរាជ្យអាជ្ញា គួរបំពេញមុខងាររបស់ខ្លួន ដោយមិនលំអៀង និងគ្មានការរើសអើង ហើយគួរផ្តល់ការយកចិត្តទុកដាក់តាមពេលសមគួរ ចំពោះការកាត់ទោស បទឧក្រិដ្ឋ ដែលបានប្រព្រឹត្តិដោយមន្ត្រីសាធារណៈ[64] ។ នៅពេលកាត់ទោសមន្ត្រីអនុវត្តច្បាប់ តុលាការ គួរសម្រេចរឿងដោយមិនលំអៀង ដោយគ្មានការដាក់កម្រិត គ្មានឥទ្ធិពលមិនសមរម្យ គ្មានគ្រឿងលើកទឹកចិត្ត គ្មានសម្ពាធ គ្មានការគម្រាមកំហែង ឬជ្រៀតជ្រែក ដោយផ្ទាល់ឬដោយប្រយោល[65] ។ គួរនាំខ្លួនចុងចោត នៅចំពោះមុខតុលាការធម្មតា ឬសាលាក្តី ហើយការកាត់ទោសត្រូវមានការការពារយុត្តិធម៌ ដែលបានធានាយោងទៅតាមច្បាប់អន្តរជាតិ

---

[61] ម៉ាកេននិងអ្នកដទៃ *v.* ចក្រភពអង់គ្លេស

[62] តុលាការសិទ្ធិមនុស្សអឺរ៉ុប,*Isayeva v. Russia*, អនុវត្តលេខ ៥៧៩៥០/០០, ២៤ កុម្ភៈ ២០០៥។ សូមមើលផងដែរ A/HRC/26/36, កឋាខណ្ឌ ៨០

[63] គោលការណ៍ ២៤ នៃគោលការណ៍មូលដ្ឋានគ្រឹះ

[64] គោលការណ៍ណែនាំ ១៣ (ក) និង ១៥ នៃគោលការណ៍ ស្តីពីតួនាទីព្រះរាជ្យអាជ្ញា

[65] គោលការណ៍ ២ នៃគោលការណ៍មូលដ្ឋានគ្រឹះ ស្តីពីឯករាជ្យភាព នៃតុលាការ

៩៤. បន្ថែមទៅលើការធានានូវគណនីយ្យភាព តាមរយៈដំណើរការរបស់តុលាការ រដ្ឋគួរតែអនុវត្តការពិនិត្យពិច័យបន្ថែម ទៅលើបញ្ហាដែលមិនមែនជាតុលាការ រួមមានដំណើរការការស៊ើបអង្កេតផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព និងស្ថាប័នពិនិត្យពិច័យដែលឯករាជ្យ។ ប្រព័ន្ធទាំងនេះ គួរប្រតិបត្តិបន្ថែម ដែលមិនមែនជាជម្រើសទៅលើដំណោះស្រាយស្របច្បាប់ នៃផ្នែកឧក្រិដ្ឋកម្ម ផ្នែកសាធារណៈ ឬឯកជនចំពោះការប្រព្រឹត្តខុសរបស់នគរបាល[66] ។ តួនាទី របស់ស្ថាប័នត្រួតពិនិត្យដើម្បីបុព្វហេតុពលរដ្ឋ គួរតែអនុវត្ត ដោយកិច្ចការរបស់មន្ត្រីស្ថាប័ន

៩៥. ទាក់ទងនឹងមធ្យោបាយដោះស្រាយ រដ្ឋត្រូវផ្តល់សំណង ចំពោះជនរងគ្រោះពីអំពើឬការភ្លេចភ្លាំងដែលអាចជាទង្វើរបស់រដ្ឋ និងជាការរំលោភធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិស្តីសិទ្ធិមនុស្ស ឬការរំលោភធ្ងន់ធ្ងរលើច្បាប់អន្តរជាតិស្តីពីមនុស្សធម៌[67] ។ សំណងគួរតែសមាមាត្រទៅនឹង ទំហំនៃការរំលោភ និងគ្រោះថ្នាក់ដែលទទួលរង និងរួមបញ្ចូលសារធាតុ នៃបដិទាន ការសងសំណង នីតិសម្បទា ការពេញចិត្ត និងការធានានូវរបស់មិនមែនជាសំណង ព្រមទាំង ការទទួលបានព័ត៌មាន ដែលទាក់ទងនឹងយន្តការដោះស្រាយការរំលោភនិងសំណង[68]

៩៦. **អនុសាសន៍អនុវត្តៈ**

(ក) រដ្ឋ គួរធានា ដោយយោងតាមច្បាប់និងការអនុវត្តជាក់ស្តែង ថា មន្ត្រីអនុវត្តច្បាប់ មិនមានអភ័យឯកសិទ្ធិ រួចខ្លួនពីការទទួលខុសត្រូវបទឧក្រិដ្ឋ ឬរដ្ឋប្បវេណី ចំពោះករណីការ ប្រព្រឹត្តិខុសវិន័យ

(ខ) រដ្ឋ គួរបង្កើត និងផ្តល់មូលនិធិ ចំពោះការពិនិត្យពិច័យមិនមែនតុលាការបន្ថែមទៀត រួមមានដំណើរការស៊ើបអង្កេតផ្ទៃក្នុងដោយប្រសិទ្ធភាព និងស្ថាប័នត្រួតពិនិត្យឯករាជ្យ ដែលមានលក្ខន្តិកៈ ។ ប្រើសិនមានហេតុផល ត្រូវជឿថាមានបទឧក្រិដ្ឋមួយត្រូវបានប្រព្រឹត្តិ ត្រូវប្រគល់រឿងនេះជាបន្ទាន់ ទៅអាជ្ញាធរ ដែលមានភារកិច្ចសម្រប់បើការស៊ើបអង្កេតត្រឹមត្រូវនិងពេញលេញ

(គ) មន្ត្រីអនុវត្តច្បាប់ ដែលស្ថិតក្រោមការស៊ើបអង្កេត ទាំងខាងក្នុងនិងក្រៅមិនត្រូវចាត់តាំងឲ្យបំពេញភារកិច្ចទេ រហូតដល់បញ្ចប់ការស៊ើបអង្កេត ហើយបញ្ជាក់ថាមន្ត្រីនោះ មិនបានប្រព្រឹត្តទោសកំហុសទេ

66 ក្រុមប្រឹក្សាអឺរ៉ុប, ស្នងការសម្រាប់សិទ្ធិមនុស្ស, “មតិរបស់ស្នងការ ចំពោះសិទ្ធិមនុស្ស ទាក់ទងនឹងការកំណត់ដោយឯករាជ្យនិងប្រសិទ្ធភាព នៃបណ្តឹង ប្រឆាំងនឹងនគរបាល” (១២ មីនា ២០០៩), កឋាខណ្ឌ ២៥

67 គោលការណ៍ ១៥ នៃគោលការណ៍មូលដ្ឋានគ្រឹះ និងគោលការណ៍ណែនាំ

68 គោលការណ៍ ១១ នៃគោលការណ៍មូលដ្ឋានគ្រឹះ និងគោលការណ៍ណែនាំ

(ឃ) រដ្ឋ គួរផ្តល់អាណត្តិទូលំទូលាយ ដល់ស្ថាប័នពិនិត្យពិច័យ ដែលឯករាជ្យ មានសមត្ថភាព និងអំណាចទាំងអស់ ក្នុងការការពារសិទ្ធិ ដែលជាបរិបទនៃការប្រជុំគ្នា។ អាណត្តិនោះ គួរអនុញ្ញាតឲ្យស្ថាប័ន បើកការស៊ើបអង្កេត លើពាក្យបណ្តឹង របស់សាធារណជន បញ្ជូនតាមមន្ត្រីប៉ូលិស និងចាប់ផ្តើមស៊ើបអង្កេត ដោយខ្លួនឯង ប្រើសិនសាធារណជនចង់ធ្វើដូច្នេះ។ ស្ថាប័ន គួរស៊ើបអង្កេតរាល់ករណីទាំងអស់ ទៅលើការប្រើប្រាស់កម្លាំង ដោយមន្ត្រីអនុវត្តច្បាប់។ ស្ថាប័នត្រួតពិនិត្យ គួរមានអំណាច ស៊ើបអង្កេតពេញលេញ ហើយពាក្យបណ្តឹង គួរតែដោះស្រាយជាបន្ទាន់ ដោយត្រឹមត្រូវ យុត្តិធម៌ និងជាសត្យានុម័ត យោងតាម ការវិនិច្ឆ័យច្បាស់លាស់

(ង) រដ្ឋ គួរជំរុញលើកទឹកចិត្ត និងសម្រួលដល់ភ្នាក់ងារអនុវត្តច្បាប់ ដើម្បីធ្វើការពិនិត្យឡើងវិញជាបន្ត គ្មានការប្រជែងអំពីប្រតិបត្តិការឈ្លបយកការណ៍ ប្រសិនអាច គឺ ធ្វើដោយភ្នាក់ងារអនុវត្តច្បាប់មួយផ្សេងទៀត។ ការពិនិត្យឡើងវិញបែប នេះ គួរធ្វើឡើងជាបន្ថែម ហើយមិនដកហូតចេញ នូវកាតព្វកិច្ចរបស់រដ្ឋ ដើម្បីបង្កើតយន្តការពិនិត្យឡើងវិញដោយតុលាការឯករាជ្យ សម្រាប់ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មនៃការរំលោភសិទ្ធិមនុស្ស

(ច) រដ្ឋ គួរពិចារណា អំពីសក្កានុភាព និងបច្ចេកវិទ្យាទំនាក់ទំនង និង ព័ត៌មានវិទ្យា ដូចជាម៉ាស៊ីនថតពាក់ជាប់នឹងខ្លួន ដែលជាបច្ច័យចំពោះគណនីយ្យភាព សម្រាប់ការ រំលោភបំពានដោយបុគ្គលិកអនុវត្តច្បាប់ នៅក្នុងបរិបទនៃការប្រជុំ។

## III. សេចក្តីសន្និដ្ឋាន

៩៧. ការប្រជុំ អាចដើរតួនាទីយ៉ាងសំខាន់ជាយុជីវិតនៅក្នុងការការពារ និងបំពេញ នូវសិទ្ធិមនុស្ស និងជីវភាពសង្គមប្រជាធិបតេយ្យ។ គេមិនគួរមើលឃើញ ការប្រជុំ ថាជាការគំរាមកំហែងទេ ។ ផ្ទុយទៅវិញ គួរមើលឃើញថាជាមធ្យោបាយមួយ នៃកិច្ចសន្ទនា ដែលរដ្ឋគួរតែចូលរួម[69] ។ ទោះជាយ៉ាងណាក្តី ការធានាឲ្យបាន នូវកិច្ចការពារសិទ្ធិជាច្រើនដែលកើតឡើង ក្នុងបរិបទប្រជុំគ្នា អាចផ្តល់នូវភាពប្រឈម។

៩៨. អនុសាសន៍សម្រាប់អនុវត្តជាក់ស្តែងទាំងនេះ ផ្តល់ចំពោះរដ្ឋ អំពីការណែនាំ អំពីវិធីសាស្ត្រ ក្នុងការបំពេញកាតព្វកិច្ច ការពារនិងលើកស្ទួយសិទ្ធិមនុស្ស ក្នុងបរិបទ ប្រជុំ។ ទោះជាយ៉ាងណាក្តី តម្លៃអនុសាសន៍ នឹងសម្រេចផលពេញលេញទៅបាន

[69] សូមមើល សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ២២/១០ និង A/៦៨/២៩៩, កឋាខណ្ឌ ១៧

លុះត្រាតែអនុវត្តដោយត្រឹមត្រូវនៅថ្នាក់ជាតិ។ វាទាមទារនូវវិធានការប្រុងប្រយ័ត្ន លើផ្នែករបស់រដ្ឋ អង្គការអន្តរជាតិ សហគ្រាសអាជីវកម្ម និងសង្គមស៊ីវិល។ អង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសិទ្ធិមនុស្ស និងតាមរយៈការពិនិត្យឡើងវិញជាសាកលតាមកាលកំណត់ និងយន្តការពិសេសៗដទៃទៀត ព្រមទាំងតាមរយៈស្ថាប័នសន្ធិសញ្ញា និងស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ គួរតែសង្កេតការ អំពីការអនុវត្ត ទៅតាមអនុសាសន៍នេះ និងគួរបន្តខិតខំប្រឹងប្រែង ដើម្បីបរិយាយល្អិតល្អន់អំពីបទដ្ឋាននីតិអន្តរជាតិ ចំពោះការប្រជុំ ។